CEN
CAMBODIA EXPRESS NEWS

# រឿង

# ឡាចសក់ក្រអូប

ប៊ីវ ឆៃលាង

ប្រលោមលោក
ក្នុង
ការផ្សងព្រេង

ព.ស ២៥១០ គ.ស ១៩៦៧

## ១
## ក្រុងកម្ពុជាធិបតី

ព្រះពុទ្ធសករាជ ២៧៧ កន្លងទៅហើយ ។ កាលនោះប្រទេសខ្មែរយើងទើបនឹងមានឈ្មោះហៅថា "កម្ពុជា" បន្ទាប់ពីឈ្មោះហៅថា "គោកធ្លក" ។

នរណាឱ្យឈ្មោះគោកធ្លកនេះ ? នរណាប្រែគោកធ្លកជាកម្ពុជាវិញ ?

យើងសូមជូនប្រវត្តិនគរគោកធ្លកនិងកម្ពុជា ជាសង្ខេបតាមព្រះរាជពង្សាវតាដូចតទៅ :

កាលក្នុង គ.ស ១៤៤ នៅជិតជើងភ្នំដងរែកប្របឆ្នេរសមុទ្រ មានព្រះមហាក្សត្រចាមមួយព្រះអង្គទ្រង់ព្រះនាមព្រះបាទ យ៉ាយ៉ៅ វ័រ្ទន ព្រះជន្ម ២០វស្សា ។ ស្ដេចសន្ទូតដើមធ្លកមួយដើម ជាចារីកព្រះនគរ ទើបទ្រង់តាំងនាមព្រះនគរឱ្យហៅថា "គោកធ្លក" ដោយហេតុ ដើមធ្លកដុះនៅកោះនោះ ។

ព្រះចៅយ៉ាយ៉ៅវ័រ្ទន កាន់សាសនាព្រាហ្មណ៍ សំពះព្រះវិស្ណុ គឺព្រះឥសូរ, ព្រះនារាយណ៍ ។

ទ្រង់សោយរាជ្យសម្បត្តិបាន ៥០ឆ្នាំ ក៏ចូលសុវណ្ណគតទៅ ។ បន្ទាប់ពីនោះមក មានព្រះមហាក្សត្រចាមបីព្រះអង្គទៀត ទ្រង់បន្តរាជសម្បត្តិនៅកោះគោកធ្លក ។

លុះដល់ព្រះពុទ្ធសករាជ ២៧៧, ព្រះថោងជាព្រះរាជបុត្រព្រះបាទអាទិច្ចវង្ស ព្រះជន្ម ៤៦ ទ្រង់ឡើងគ្រងរាជសម្បត្តិនៅប្រាសាទ មហានគរធំ តាំងនាងធារាវតី កូនស្ដេចភុជង្គនាគជាព្រះអគ្គមហេសី ។

មុនព្រះថោងឡើងគ្រប់គ្រងផែនដី ស្ដេចនាគ និងសេនាដ៏មានតេជៈបារមីរបស់ព្រះអង្គ បានសំដែងឫទ្ធិស្រូបទឹកសមុទ្រឱ្យស្រកចុះ នោះកោះ

គោកធ្លក ក៏ក្លាយទៅជាផែនដីមានផ្ទៃធំទូលាយ និម្មិតជាព្រះបរមរាជវាំង មានលំពែងវែងវង់ជុំវិញ ៧ជាន់ នៅទីក្រុង គល់ធ្លក និម្មិតជាប្រាសាទតូច-ធំ ផ្សេងៗ ថ្វាយព្រះរាជសុណិសា និង ព្រះរាជបុត្រីព្រះអង្គ ។

ខណៈនោះ, ស្ដេចនាគទ្រង់តាំងនាមព្រះនគរឱ្យហៅថា "ក្រុងកម្ពុជាធិបតី" រៀងរហូតមក ។

ក្រោយមក, ព្រះបាទសម្ដេចកុមេរុរាជ គឺព្រះថោងនេះឯង ទ្រង់ និង ព្រះមហេសីបានលើកសេនានិករចាកចោលមហានគរធំ ត្រឡប់ឡើងមកគង់នៅក្នុងមហារាជវាំង ដែលព្រះបិតាក្មេកបាននិម្មិតនោះវិញ ។

រឿង នាងសក់ក្រអូប គឺជារឿងកើតឡើងនៅក្នុងរជ្ជកាលនៃព្រះថោងកុមេរុរាជនេះ ។

## ២

## ត្រីច្រាំពណ៌

សែងព្រះសុរិយាកំពុងតែបង្អោនចុះនៃតេជោធាតុ ដែលបានដុតកំដៅស្លឹកឈើ ស្មៅនិងជីវិតមនុស្ស សត្វតាំងពីព្រឹកម្ល៉េះ ។

ទេសភាពមាត់សមុទ្រ តាមជួរភ្នំដងរែកហាក់ដូចជាបង្ហំរូតវាំងននវិចិត្ររបស់ខ្លួន ចាំគោរពនភមណី ដែលនឹងយាងចូលអស់ស្ដង្គត ។

ជលសាគរនៅនឹងថ្កល់លើដំណេក ។ មានរលកតូចៗបានទៅបោកខ្លួនផ្ទប់នឹងច្រាំងជាធម្មតា ។

រមណីយដ្ឋាននេះ ជាទីស្មសានដាច់ស្រយាលពីអ្នកនគរ ។

ប៉ុន្តែ គង់មានមនុស្សពីរនាក់ជាសាក្សីនៃទេសភាព ពេលសាយណ្ហសម័យនាថ្ងៃនេះ ។

នៅលើទីវាលមួយ ក្បែរច្រាំងសមុទ្រនោះ, តាចាស់ម្នាក់អាយុប្រមាណជិត ៦០ឆ្នាំ, ពុកមាត់ពុកចង្កាដុះស្រមូម ស្លៀកសំពត់ចងក្បិន ខ្លួនទទេ, សក់ក្បាលធ្លាក់មកលើ ក, កំពុងជញ្ជូនដុំថ្មតូចៗទៅគរលើផ្នូរខ្មោចមួយ ដែលជាទីស្រឡាញ់ និងជាទីរព្ញករបស់គាត់ នៅប្របនោះ, មានរទេះមួយឈប់ស្ងៀម, គោទាំងពីរកំពុងស៊ីស្មៅក្នុងតុណ្ហីភាព ។

តាខ្វែកដាក់ថ្មមួយដុំនៅលើក្បាលដំណេកផ្នូរ គាត់ក្រោកឈរ យកដៃតប់ចង្កេះ រួចស្រែកហៅទៅនរណាម្នាក់នៅក្នុងរទេះថា :

-វណ្ណនី មកកូន ! ល្ងាចហើយ, មកលាផ្នូរទាំងអស់គ្នា យើងនឹងអាលត្រឡប់ទៅផ្ទះវិញ ។

-ចាំះ ! លោកឪពុក ... នាងកញ្ញាឆ្លើយសម្លេងស្រួយផ្អែម, នាងបញ្ចេញភ័ក្ត្រដ៏បវររបស់នាងពីក្នុងយាន ហើយដើរតម្រង់មករកផ្នូរ ។

តាខ្វែកនិងវណ្ណនី ឈរសំដែងកាយវិការគោរពវិញ្ញាណក្ខន្ធបុគ្គលដែលចែកឋានទៅកាន់លោកនាយ ចំនួន ១០ ឆ្នាំ កន្លងទៅហើយ ។

វេលានោះ, តាខ្វែកក៏បង្ហូរវិញ្ញាណរបស់គាត់ទៅកាន់អតីតកាលយ៉ាងកំសត់ទុគិត និងឃោរឃៅអស្ចារ្យ ដែលឆ្លាក់ជាប់មិនភ្លេចនៅក្នុងសតិអារម្មណ៏របស់តាចាស់ ។

នេះជារឿង ដែលតាកំសត់រំលឹកឡើងកាលពីគាត់នៅអាយុ៤៥ ឆ្នាំ ហើយដែលលោកអ្នកអានជាទីគោរពរបស់យើង ត្រូវធ្វើដំណើរជាមួយអ្នកនិពន្ធទៅជួបតាខ្វែក ក្នុងសម័យផ្សងព្រេងរបស់គាត់ដូចតទៅ :

សូរខ្យល់នារដូវវស្សា បានបន្លឺយ៉ាងខ្លាំងចំនួនពីរថ្ងៃមកហើយ ។ ភ្លៀងធ្លាក់គ្មានឈប់ ចេះតែរលឹមជាប់ ។ ព្រះទិនករក៏មិនងាយនឹងបង្ហាញដួងរស្មីដល់ពិភពលោកដែរ ។

ក្នុងស្ទឹងមួយនាជើងភ្នំគូលែន ស្រមោលទូកមួយអុំដោយដៃអ្នកនេសាទម្នាក់ កំពុងរអិលល្បឿនសន្សឹម១ចូលខាង ។

-វ័ណ្ណនី ! វ័ណ្ណនី ! មកយកត្រីអូន ! អ្នកនេសាទស្រែកហៅប្អូនពីមាត់កំពង់ ដោយសេចក្ដីរីករាយ ។

-ចាំះបង ! ខ្ញុំទៅហើយ. វ័ណ្ណនីឆ្លើយ ។

ដោយគ្រាប់ព្រះភិរុណមិនព្រមបាត់ស្ងាត់នោះ, នាងកុមារីក៏យកចង្អេរគ្របក្បាល, ដៃកាន់កញ្ច្រែងមួយ រត់ចុះទៅដល់ទូកភ្លាម ។

អ្នកកម្លោះវ័ណ្ណនាជាបង កាលឃើញប្អូនតូចមកដល់ ក៏រាក់ទាក់លើកត្រីពីក្នុងទូក ដាក់ទៅក្នុងកញ្ច្រែង រួចសួរនាងថា :

-វ័ណ្ណនី ! ម៉ែដាំបាយឆ្អិនហើយឬនៅ ? ល្ងាចនេះបងឃ្លានបាយណាស់ !

ចាំះបង ! ម៉ែដាំឆ្អិនហើយ រង់ចាំតែត្រីនឹងស្លប៉ុណ្ណោះ ។

វ័ណ្ណនីទើបនឹងបានអាយុ ៩ ឆ្នាំ សម្លេងនាងស្រួយពិរោះ ។

-អើ ! បើដូច្នោះ ទៅអូន ! បងស្ពាយសំណាញ់ ។

ឮសូរតែគ្រាំ ! នាងតូចរអិលជើងលើគែមទូក ហើយធ្លាក់ទៅក្នុងទឹក ឯកញ្ច្រែងក៏ត្រូវខ្សែទឹកកួចទៅបាត់ ត្រីរួចអស់ឥតសល់ ។

វ័ណ្ណនា លោតប្រួងដូចសត្វអកទៅស្រង់ប្អូនទាន់មកដាក់លើទូកវិញ ។ នាងភ័យណាស់ឈ្លក់ទឹកបន្តិចទៅហើយ !

-កុំតែបងរហ័សចាប់ខ្ញុំទាន់ កុំអីខ្ញុំស្លាប់ស្រេច... ហ៊ឺ ! ត្រីរួចអស់រលីង សមម៉ែវាយមិនខាន !

-កុំទៅគិតអាត្រីនោះ រួចក៏រួចទៅ ឱ្យតែអូនមានជីវិត បងអត់បាយមួយល្ងាចនេះក៏បានដែរ ។

-ទៅផ្ទះបង ! ប្រហែលជាបងរងាខ្លាំងហើយ !

-ឈប់វ័ណ្ណនី ! បងឮសូរត្រីមួយបម្រះក្នុងទូក...

វ័ណ្ណនាយកដៃទៅកក្កូររកត្រី តែមិនប្រទះមច្ឆាជាតិណាមួយសោះ ។ អ្នកដកដង្ហើមធំ ហើយគិតថា :

-ផ្ដាសសោះតែម្ដង, ទឹកបាតទូកក្រឡុកនឹងរលក ឯងស្មានតែត្រីបម្រះ ហាំ១ ! ហាំ១ !...

សពិង្គកាយយុវជន កាន់តែរងាខ្លាំងឡើង១ ថ្គាមញ័ររណ្ដំគ្នាឮ កិក ! កិក ! បើអ្នកទៅបង់សំណាញ់ទៀត ក៏វាហួសពេលទៅហើយ ។

យុវជនឈានជើងឡើងទៅលើគោក ស្រាប់តែក្នុងបាតទូកអ្នកមានសម្លេងត្រីមួយបក់កន្ទុយ ខ្ជិច ! ខ្ជិច ! ហាក់ដូចស្រែកហៅឱ្យអ្នកត្រឡប់ទៅវិញ ។

-យី អញរាវរកអម្បាញ់មិញ ម្ដេចមិនឃើញ ? វ័ណ្ណនី ! វ័ណ្ណនីឈប់សិន ! បងទៅមើលម្ដងទៀត...

វ័ណ្ណនាទំលាក់សំណាញ់ចោល រួចលោតផ្លោតទៅក្នុងជលយាន អ្នកឃើញត្រីមួយមែន ។

-អៃយ៉ា ! ត្រី ហាំ ! ហាំ !...

មាណពចាប់ត្រីបាន មានចិត្តត្រេកអរជាពន់ពេក ត្រីនោះមានទំហំប្រមាណបីធ្នាប់ដៃប៉ុណ្ណោះ, អ្នកកាន់វាក្ដាប់ជាប់ នាំប្អូនដើរតម្រង់ទៅខ្ទមកំសត់ ។

កាលឡើងមកដល់លើផ្ទះមាតាកុមារទាំងពីរ បានចៅរ៉ៅមកសួរថា:

-ម៉េចកូន ! ឯណាត្រី ?

វ័ណ្ណនីដាក់មុខស្រពោន រួចក៏ឆ្លើយថា :

-ខ្ញុំធ្វើឱ្យរួចអស់ហើយម៉ែ !,,,

មីងវ័ណ្ណខឹងណាស់, មិនបានគិតវែងឆ្ងាយ, ប្រទះរំពាត់ក្បែរនោះ ក៏ចាប់មកវាយកូនស្រី ខ្វាប់ ! ខ្វាប់ !

វ័ណ្ណនា បោះត្រីដែលកាន់នៅដៃចោលទៅលើគំនរសំណាញ់ក្បែរមាត់ទ្វារ រួចស្ទុះទៅឃាត់ម្ដាយ ។ អ្នកលុតជង្គង់សំពះថា :

-កូនសូមលើកទោសឱ្យវ័ណ្ណនីម្ដង,,, ភ្លៀងច្រើនអូនរអិលជើងធ្លាក់ទៅក្នុងទឹក របូតកញ្ច្រែងត្រីពីដៃទៅ កុំតែខ្ញុំលោតចាប់អូនទាន់ ម្ល៉េះអូនស្លាប់ទៅហើយ, អូនមិនទាន់បាត់ភ័យផង ម៉ែវាយថែមយ៉ាងនេះ ម៉ែឈ្មោះថា គ្មានសីលធម៌និងព្រហ្មវិហារធម៌ដល់បុត្រទេ !

ស្ដាប់ដូច្នោះ មីងវ័ណ្ណរបូតរំពាត់ពីដៃ, គាត់ស្ទុះទៅចាប់វ័ណ្ណនី មកឱបក្រសោបនៅទ្រូងដ៏សែនវេទនារបស់គាត់, គាត់ថ្ងូរតិចៗថា :

-ឱកូនស្រីម៉ែ !... ម៉ែមិនគួរវាយកូនឥតពិចារណាដូច្នេះសោះ ហ្ន៎! បើកូនស្លាប់ ម្ដាយមុខជាមិនរស់ទេ,,, ខ្មោចឪពុកកូនបានផ្ដាំម្ដាយថា បើទោសដល់ស្លាប់ឱ្យត្រឹមតែវាយ, បើទោសវាយ ឱ្យត្រឹមតែស្ដីជេរ ។ ខណៈនោះ ម្ដាយភ្លេចពាក្យបណ្ដាំរបស់ឪឯង,,,

នាងយំឱបកូនទាំងពីរ, វ័ណ្ណនីយំអាណិតម្ដាយ វ័ណ្ណនីដើរទៅយកត្រីនៅលើសំណាញ់នោះ មកបង្ហាញមាតា :

-ម៉ែ ! សល់ត្រីមួយ យើងយកទៅស្លបានដែរ !

-យី ! កូនត្រីអីប្លែកម្ល៉េះ ? នែ ! មានពណ៌ល្អផង,,,

នាងវ័ណ្ណនី ផ្លាស់សំពត់អាវរួច។ នាងកាន់ចង្ក្រៀងមួយមកដល់ក៏ភ្ញាក់នឹងត្រី ដែលបងបង្ហាញម្ដាយនោះ មានរូបឆោមគួរជាទីស្រឡាញ់ ។

-ម៉ែ ! ត្រីនេះនៅរស់ ! កុំធ្វើវាអី ចិញ្ចឹមវាទុកឱ្យល្អមើលទៅ!

មីងវ័ណ្ណឮសំដីកូនស្រីដូច្នោះ ក៏បណ្ដោយតាមបំណងនាងថា :

-អើបើដូច្នោះ កូនឯងទៅយកក្រឡខាងក្នុងដាក់ទឹកបន្ដិចមក!

វ័ណ្ណនីបានក្រឡទឹកមក ក៏លែងមច្ឆាជាតិឱ្យហែល ។

ល្ងាចនេះ, គ្រួសារមីងវ័ណ្ណ ក៏បរិភោគអាហារតាមការក្រខ្សត់។

វេលាព្រឹកស្អែកឡើង, មេឃស្រឡះ, ព្រះអាទិត្យរះឡើង ចោលរស្មីភ្លឺផ្លេកពេញទាំងភពមណ្ឌល ។

ពេញមួយថ្ងៃនេះ, មីងវ័ណ្ណនិងបុត្រទាំងពីរបានសង្កេតឃើញត្រីដែលចិញ្ចឹម មានពណ៌ប្លែកៗពីគ្នាដល់ទៅប្រាំយ៉ាង ទើបគាត់ដាក់ឈ្មោះត្រីនោះថា "ត្រីប្រាំពណ៌" ។

## ៣

## នាងកែវបុប្ផា

វ័ណ្ណនា មិនគ្រាន់តែមានកិច្ចរវល់ក្នុងការនេសាទប៉ុណ្ណោះទេ អ្នកជាប់ធ្វើការងារស្រែទៀត ។ រាល់ព្រឹក មាណពភ្ញាក់ពីព្រលឹម កាន់ចបទៅកាប់ដីទប់ភ្លឺស្រែ ឬទៅបាចទឹកបញ្ចូលថ្នាល ។

កម្លោះ សប្បាយណាស់ ដោយឃើញសំណាបលូតលាស់ឡើងខៀវខ្ចីពេញផ្ទៃស្រែ ។

ព្រឹកនេះវីណ្ណនាស្រែកច្រៀងរីករាយនឹងធម្មជាតិ, អ្នកសង្ឃឹមនឹងបានកាន់កណ្ដៀវ ទៅច្រូតកាត់ស្រូវដែលនឹងទុំឡើងក្នុង ៦-៧ ខែ ខាងមុខនេះបន្ទាប់ពីដកស្ទូង ។

អរុណោទ័យ បើកស្រទាប់ពណ៌លឿងខ្ចីឯបូព៌ាទិស, មាណពដើរលើភ្លឺស្រែ ដៃកាន់ពូថៅមួយតម្រង់ទៅមើលទឹកក្នុងថ្នាលផ្សេងទៀត ។

មុនព្រះអាទិត្យរះឡើងពេញពន្លឺ សូរត្រដោកគោ, ត្រដោកក្របីនៅលើទីវាលស្មៅក្បែរជើងភ្នំ បានចោលភេរវសញ្ញាដល់សោត ទ្វារវីណ្ណនា ។ អ្នកបារម្ភជានិច្ចក្រែងហ្វូងពាហនៈទាំងនោះ បោលឬនាំគ្នាមកលុកលុយស៊ីសំណាបខ្លួន ។

មិនយូរប៉ុន្មាន អ្នកក្រឡេកឃើញគោមួយហ្វូង រត់ប្រសាចពីទីវាលនោះមកដល់ស្រែអ្នក ។ ដំណើរវាគឺប្រុងឆ្លងទីផ្សេងទៀត តែប្រទះសំណាបគោទាំងប៉ុន្មានក៏ស៊ីសំណាបដ៏ទន់ខ្ចីស្រឹប១អស់ជាច្រើនកន្លែង ។

ចៅមាណព ឆ្លួលឆេះពោរពុះទៅដោយទោសៈ អ្នកស្រែកដេញគោហើយរត់បណ្ដើរ ជេរប្រទេចពួកគោបោលបណ្ដើរថា :

-គោអ្នកណាវើយ ! ស៊ីសំណាបអញអស់ហើយ គោអាកាប់ក ណាអេះ ! អ្ហុយ !... អ្ហុយ ! !

ទោះខំអំពាវនាវស្រែកហៅម្ចាស់គោ និងក្តៅអន្ទះអន្ទែងយ៉ាងណាក៏ដោយ ក៏អ្នកមិនអាចឃាត់ឃាំងអំពើវាតត្បាតនៃសត្រូវទាំងនោះបានឡើយ ។

ខឹងណាស់ ដេញគោមិនរត់, វីណ្ណនាលើកពូថៅចោលទៅ, ផ្លែពូថៅទៅមុខខ្នងគោមួយ ឈាមហូររហាម ។

-នែអ្នកនេះ ម្ដេចហ៊ានចោលគោខ្ញុំឱ្យមុតចេញឈាមយ៉ាងនេះ ? សម្លេងមួយស្រួយស្រោកបន្លឺឡើងនៅក្រោយខ្នងអ្នកកម្លោះ ។

យុវជនងាកមុខទៅ ក៏ឃើញនារីម្នាក់អង្គុយលើខ្នងសេះ នៅជិតនាងមានបុរសពីរនាក់ជិះសេះចោលភ្នែក និងទឹកមុខឃោរឃៅមករកអ្នក ។

នាងកញ្ញាមិនទាន់ថាអ្វីទៀត, ដេញជំនិះជ្រុលទៅក្បៀងហ្វូងគោឱ្យផុតពីថ្នាល រួចនាងត្រឡប់មកវិញ, នាងបង្គាប់បាវរបស់នាងថា :

-វើយចាប់វាទៅ, ត្រូវឱ្យវាសងគោយើង !

ទាសាទាំងពីរលោតទៅដី ហើយដេញចាប់វីណ្ណនា, វីណ្ណនាភ័យណាស់ ខំដោះខ្លួនរត់ ។ អ្នកទាំងពីរត្រឡប់មកយកសេះជិះ នារីដែលនៅលើខ្នងជំនិះស្រាប់នោះ ស្រែកថា :

-វារត់សំដៅខ្ទមវាឯណោះហើយ ! យើងដេញ,,,

វីណ្ណនារត់លឿនស្លុង, មកដល់ផ្ទះក៏ឡើងតាំង១ទៅយកដាវមកកាន់នៅដៃ, ម្ដាយមិនដឹងរឿង, ភ័យញ័ររន្ធត់សួរកូនថា :

-ស្អី ! ស្អី ! អាវីណ្ណនា ! រឿងអីកូន !...

-ម៉ែ... រឿងធំ, គេដេញចាប់កូន !

ថាប៉ុណ្ណោះ មាណពលោតទៅដីព្រួស, អ្នកជិះសេះទាំងបីនាក់ មកដល់ល្មម, ចាកជំនិះ ខ្វែកនិងស្ទាំងជាទាសាយុវតីហូតដាវខ្វាក, វីណ្ណនាស្រែកថា :

-ម៉េចចង់លអាវុធនឹងខ្ញុំម្ដងឬ ? គោពួងឯងស៊ីសំណាបខ្ញុំអស់ បានជាខ្ញុំចោល, ម៉េចពួងឯងលែងគោឱ្យស៊ីសំណាបគេ តាមអំពើចិត្តយ៉ាងនេះ ? ខ្ញុំមិនសុខចិត្តប្រគល់ខ្លួនឱ្យពួងឯងចាប់ទេ ! ត្រូវប្ដឹងរកខុស ត្រូវឱ្យឃើញសិន !

មាណវីមុខក្រហម គំហកថា :

-នៅមាត់រឹងទៀត, ឯងជាមនុស្សព្រហើនកោងកាចណាស់ បើអ្នកឯងមិនចង់ឱ្យគោយើងស៊ីស្រូវអ្នកឯង, អ្នកឯងត្រូវធ្វើរបងឱ្យខ្ពស់ឡើង, ឯងចោលគោយើងនេះ គឺឯងត្រូវមានទោស !

ខ្មៅកនិងស្នាំងលូកអាវុធផ្ទងទៅ, កម្លោះរងជាប់, ក្នុងវ័យ ២៣ ឆ្នាំ វ័ណ្ណនាពូកែខាងអាវុធដាវគួរសមដែរ តម្រិះខាងការពារខ្លួន អ្នកបានរៀនចេះពីគ្រូក្នុងតំបន់ភ្នំគូលែន តាំងពីអ្នកនៅកុមារម្ល៉េះ ។

នាងកែវបុប្ផា ជាចៅហ្វាយស្រីរបស់ខ្មៅកនិងស្នាំង ឈរកាន់រំពាត់ខ្សែតីមួយ, ចងចិញ្ចើមយ៉ាងកាចទៅរកវ័ណ្ណនា ។

ដាវទាសាទាំងពីរ កញ្ច្រោលទៅលើមុខអាវុធវ័ណ្ណនាយ៉ាងខ្លាំង ធ្វើឱ្យបេះដូងមីងវ័ណ្ណនិងនាងវ័ណ្ណនី ឱ្យកើតចិត្តរំជើបរំជួលឥតព្រំដែន ។

កាប់គ្នាវីវក់ បែកផុកពេញមុខផ្ទះ ទីបំផុតអ្នកកម្លោះយើង ទម្លាក់អាវុធសត្រូវបានពីរនាក់ ថែមទាំងដាល់វាដួលផ្កាប់មុខទៅក្នុងផុកទៀត ។

កែវបុប្ផាឃើញដូច្នោះ ក៏យាររំពាត់វាយត្រូវវ័ណ្ណនា ២-៣ខ្វាប់ បែកឈាម ។ អ្នកមិនស្មាននាងមានចិត្តអប្រិយ៍ដល់ម្ល៉េះសោះ បានជាអ្នកមិនប្រុងប្រយ័ត្ន ។

មាណពមិនតដៃនឹងស្រីទេ អ្នកញញឹមទៅរកនាង, នាងយាររំពាត់ប្រុងវាយទៀត, អ្នកចាប់ដៃធីតាជាប់ :

-នាងស្រី ! រូបឆោមលោមពណ៌របស់នាង, សម្លេងយ៉ាងស្រួយផ្អែមរបស់នាង មិនសមនឹងអំពើឃោរឃៅដែលនាងបានប្រព្រឹត្តនេះទេ ! នាងឈ្មោះអ្វី ? ជាកូនចៅលោកអ្នកណា ?

នាងធ្វើមុខក្រញូវបែរមុខចេញធ្វើហី ! ដូចក្មេងងចង់បាននំច្រើន, មីងវ័ណ្ណឃើញឋានៈគេបែបខ្ពស់ គាត់ក៏ស្ទុះទៅឱបជើបកញ្ញា អង្វរថា :

-ឱ ! នាងក្រមុំល្អហើយ ! សូមនាងអាណិតមីងទៅ, យើងជាអ្នកក្រីក្រទុគិតណាស់... មីងមិនបានដឹងរឿងអ្វីទេ !

កែវបុប្ផា ដូចជាទន់ចិត្តអាណិតមីងវ័ណ្ណមួយអន្លើដែរ តែនាងនៅចងអាឃាតថ្នាំងថ្នាក់នឹងវ័ណ្ណនានៅឡើយ ។

ខ្មៅកនិងស្នាំងក្រោកឡើងមុខស្រមក សល់តែប្រឡង់ភ្នែក គួរឱ្យចង់សើចណាស់ គាត់ស្ទាបថ្គាម ស្ទាបក្បាល ។ មីងវ័ណ្ណស្ទុះទៅលួងលោមអ្នកទាំងពីរ ដោយវាចាផ្អែមពិរោះ ។

កែវបុប្ផាខ្មាសម្ចាស់ផ្ទះ ដោយពួកនាងចាញ់ថ្វីដៃ ក៏បង្គាប់ទៅទាសាថា :

-ទៅផ្ទះវិញ បើវាមិនខ្លាចទេ !

វ័ណ្ណនា ដើរទៅជិតនាងបុប្ផា លាត់ដៃឱ្យនាងមើលស្នាមរំពាត់ រួចពោលថា :

-នាងឃើញទេ ? នែនាង ! បំណាច់នាងវាយខ្ញុំម្ដង នាងមិនប្រាប់ឈ្មោះដល់ខ្ញុំសោះ ! ណ្ហើយ ! រឿងអម្បាញ់មិញយើងទុកជារួចគ្នាទៅចុះ ព្រោះគោនាងស៊ីសំណាបខ្ញុំដែរ ហើយនាងវាយខ្ញុំចេញឈាមស្មើនឹងគោមើលចុះខ្ញុំមិនទាំងតបនឹងនាងផង ឥឡូវសូមនាងកុំខឹងនឹងខ្ញុំ ឡើងលេងផ្ទះខ្ញុំសិនឬ

? ឱ ! ផ្ទះខ្ញុំកំសត់ណាស់ តែបើនាងព្រម ខ្ញុំមានវត្ថុពិសេសមួយជូននាងមើលកំសាន្ត ។

-អ្វីវត្ថុពិសេសនោះ ! កញ្ញាសួរមុខស្រស់បន្តិច ។

-ត្រីប្រាំពណ៌នាងស្រី ! មីងវ័ណ្ណឆ្លើយយ៉ាងរីករាយ ។

យុវតីមើលមុខវ័ណ្ណនាដោយក្តីអាណិត កល្យាណីប្រែទឹកមុខញញឹមបញ្ចេញធ្មេញសដូចចានមកថា :

-ឯម៉េចទៅត្រីប្រាំពណ៌នោះ ? ខ្ញុំចង់ឃើញណាស់ !

-ទេ ! នាងប្រាប់ឈ្មោះដល់ខ្ញុំសិន ! កម្លោះស្រដីតបមក ។

-ចា៎ះ ! ខ្ញុំឈ្មោះកែវបុប្ផា អាណិតឱ្យត្រីនោះខ្ញុំមើលផង ត្រីប្រាំពណ៌ល្អយ៉ាងណាទៅ ខ្ញុំមិនដែលឃើញទេ !

វ័ណ្ណនាសើចរួច ក៏នាំភ្ញៀវទាំងបីនាក់ឡើងទៅលើផ្ទះ។ វ័ណ្ណនា ជាអ្នកលើកក្រឡត្រីមកបង្ហាញ ។

នាងក្រមុំបុប្ផា ឃើញត្រីភ្លាម ក៏លាន់មាត់ថា :

-យី ! ត្រីនេះល្អមែន អ្នកបងបានពីណាមក ?

ពាក្យអ្នកបងមួយម៉ាត់នេះ ឆ្លុះដល់បេះដូងយុវជន ។

វ័ណ្ណនាញញឹម ឆ្លើយទៅកញ្ញាឆើតឆាយវិញថា :

-អ្នកនាង... ខ្ញុំបង់សំណាញ់បានពីក្នុងស្ទឹងមក ត្រីនេះពេលព្រឹកពណ៌លឿងខ្ចី ថ្ងៃត្រង់ពណ៌ផ្កាឈូក ថ្ងៃរសៀលពណ៌ផ្កាស៊ីជម្ពូ ល្ងាចពណ៌ក្រហមព្រឿង យប់ពណ៌ផ្ទៃមេឃ ឱអ្នកនាង គឺជាការចម្លែកណាស់ ខ្ញុំមិនទាន់ឃើញថាត្រីនេះឱ្យផលល្អ ឬអាក្រក់យ៉ាងណានៅឡើយទេ តែថ្ងៃនេះមកមានរឿងហេតុនឹងនាងដូច្នោះ គួរឱ្យស្តាយណាស់ !

មាណវីស្រឡាញ់ត្រី ហើយស្រឡាញ់ដល់ម្ចាស់ត្រីទៀត ឮគេហៅអ្នកនាងយ៉ាងពិរោះដូច្នោះ នាងក៏នឹកអៀនខ្លួនណាស់ តែមិនជាការទាស់អ្វីទេ ព្រោះនាងយល់ថានាងនៅតូច ។ មិនដឹងជាហេតុអ្វី នាងចេះតែស្រឡាញ់ត្រីនោះ ចង់បានត្រីយកទៅផ្ទះនាង ។

កែវបុប្ផាស្រុះស្រួល ទទួលពាក្យវិញថា :

-ត្រីនេះ មិនសមនៅជ្រកនិងរស់នៅក្នុងក្រឡដូច្នោះទេ សមតែទៅនៅក្រោមដំបូលក្បឿង ក្នុងកែវវិចិត្រដ៏មានតម្លៃឯណោះវិញ !

-នាងអូន ធ្វើម្តេចវាសនាមនុស្ស ក៏ដូចវាសនាត្រីដែរ ធម្មជាតិបង្កើតរូបនិងជីវិតមក តែងមានអ្នកក្រអ្នកមាន ឯអ្នកមានប្រមូលសម្បត្តិពីអ្នកក្រទៅធ្វើមាន ។ មិនជាការទាស់ឡើយ បើនាងអូនចង់បានត្រីនេះទៅជាសម្បត្តិដ៏រុងរឿង ខ្ញុំជូនបានតែត្រូវប្តូរនឹងតម្លៃវត្ថុឯណាដែលជាទីពេញចិត្តរបស់ខ្ញុំ ។

កញ្ញាស្គាល់ជំរៅរបស់មាណព នាងធ្វើបន្ទប់បែរជាមកសួរឈ្មោះកម្លោះថា :

-អើ ! អម្បាញ់មិញសួរឈ្មោះខ្ញុំ ខ្ញុំប្រាប់ ម្តេចមិនប្រាប់ឈ្មោះខាងហ្នុងដល់គេផង ?

-អូ ! បុប្ផា... បងឈ្មោះវ័ណ្ណនា... ខ្យល់អាខាងចុងដូចគ្នា បើធ្វើមិត្តភ័ក្រក៏សម ធ្វើបងប្អូនក៏សម... ទេ ! សុំទោស ខុសគ្នាឆ្ងាយណាស់ ឱ្យខ្ញុំធ្វើខ្ញុំបំរើនាងវិញទើបសម !

ឆវីចេះតែញញឹមពព្រាយ មិនបានសង្កេតទឹកមុខខ្ញែកនិងស្មាំងដែលលួចសម្លក់ឱ្យនាងម្តងៗ ។

-ល្អមែន ! ឈ្មោះបងឯង តែចំណែកបុប្ផាមានខ្ញុំបំរើគ្រប់គ្រាន់ហើយ បើឱ្យវីណ្ណនាទៅច្រៀងលើភ្លីស្រែឱ្យខ្ញុំស្តាប់ប៉ុណ្ណោះ ប្រហែល សមជាង !

-អូ... នាងអូនឮខ្ញុំច្រៀងពី... ពីកាលណា ?

-កុំបាច់លាក់ គេមិនឮឬ ? ហ៊ឺ ! ឈប់និយាយ ខ្ញុំចាំមិនភ្លេចទេ រឿងជម្លោះរបស់យើងនេះ បើកុំតែយើងកើតហេតុនឹងគ្នា ក៏យើងមិនបានស្គាល់គ្នាដែរ ហើយខ្ញុំក៏មិនបានឃើញត្រីប្រាំពណ៌នេះដែរ ដូច្នេះយើងទុកគ្នាជាមិត្តតទៅ ដើម្បីឱ្យខ្ញុំបានមកមើលត្រីនេះទៅថ្ងៃក្រោយទៀត !

កែវបុប្ផា មានចិត្តអាណិតអ្នកកម្លោះណាស់ដោយឃើញឈាមចេះតែហូរតាមស្នាមរំពាត់នៅលើដៃអ្នកមិនឈប់ ។ កញ្ញាដោះកន្សែងឆ្នូតក្បាលរបស់នាង ទៅរុំឱ្យអ្នកថ្នមៗដោយសម្លេងថា :

-វីណ្ណនាបង ! គឺជាសេចក្តីស្តាយមួយដ៏ធំលើសលែងរបស់ខ្ញុំ ដែលខ្ញុំទុកស្នាមរបួសឱ្យបងដោយចេតនា ចូរបងលើកទោសឱ្យខ្ញុំផង ហើយចំពោះសំណាបរបស់បងនេះ ចាំខ្ញុំទៅជំរាបលោកប៉ាឱ្យសងតាមគួរ !

-ទេ ! ទេ ! កែវបុប្ផាអើយ ! យើងជាមិត្តនឹងគ្នាទៅហើយ រឿងនេះកុំយកមកនិយាយ... នរណាលោកប៉ានោះ ? ឱ្យខ្ញុំស្គាល់ផងបានទេ ?

មាណវីនៅស្ងៀម ព្រឺព្រួចក្នុងលោមា ។ នាងមិនចង់មើលមុខមិត្តថ្មីរបស់នាងឡើយ ព្រោះដួងចក្ខុគេ វង់ភ័ក្ត្រគេ និងសម្លេងគេ ចេះតែមកបំពេរ និងអង្អែលបេះដូងកំព្រារបស់នាង។ ឯមាណពវិញ វិស័យដូចអណ្តែតបាទាទៅលើនភាល័យ ពេលណាបុប្ផាចោលរស្មីញញឹម និង ខ្សែចក្ខុចំអ្នកម្តងៗ ។

ទិព្វតន់កញ្ញាមិនចង់ប្រាប់ឈ្មោះឪពុកទៅកម្លោះសោះ ព្រោះនាងមិនចង់ឱ្យគេស្គាល់ឋានៈដ៏ឧត្តមរបស់នាង ។ កែវបុប្ផាលាម្ចាស់ផ្ទះចុះមកដី វីណ្ណនាតាមមកជាមួយជាអ្នកជូនផ្លូវ ។ ធីតាឡើងលើពាជី ខ្វែកនិងស្មាំង លើខ្នងសេះនាងយករំពាត់ខ្សែតីទៅប្រឡែងលើនរៈបន្តិចៗ រួចជូនរង្វាន់សម្ផស្សញញឹមមួយជាចុងក្រោយទៅអ្នកថា :

-បងវីណ្ណនា ! នេះជាលើកដំបូងនៃជីវិតរបស់ខ្ញុំ ដែលលោកមហាសេដ្ឋីជាបិតារបស់ខ្ញុំ បានបើកច្បាប់ឱ្យខ្ញុំជិះសេះមកលេងវាលស្រែ !

កូនប្រុសមីងវីណ្ណឮឈ្មោះសេដ្ឋី ក៏ដូចជាបាត់ព្រលឹង រលត់វិញ្ញាណអស់ ព្រោះអ្នកដឹងថា សព្វថ្ងៃម្តាយអ្នកនៅជំពាក់ប្រាក់លោក សេដ្ឋីជាច្រើន បើលក់ស្រែលក់ទាំងខ្ទមនេះទៅទៀត ក៏សងលោក សេដ្ឋីមិនគ្រាន់ដែរ ឱ ! កែវបុប្ផា ! នាងជាកូនសេដ្ឋី...

ទោះជាមានខ្យល់ព្យុះ បោកចំមុខអ្នកមួយវិបស្ទើរដួលនេះក៏ដោយ វីណ្ណនាខំស៊កពាក្យមួយម៉ាត់ចុងក្រោយទៅវរលក្ខណ៍ថា :

-បុប្ផា ! នាងគឺជាភ្ញៀវទីមួយរបស់ខ្ញុំ នៃការទស្សនាត្រីប្រាំពណ៌នេះ នាងកុំនិយាយឱ្យអ្នកដទៃដឹងរឿងនេះឮទេ ?

-មិនអីទេបងសម្លាញ់ ប្អូនលាហើយ !

សេះទាំងបីបោលស្លូងទៅមុខ យុវជនឈរមើលតាមក្រោយដរាបទ្វារប្រាសាទនៃនេត្រាអ្នក លែងមើលមាណវីឃើញតែម្តង ។

## ៤

## នាងសក់ក្រអូប

ប្រាំថ្ងៃកន្លងមក... សេដ្ឋីជ្រាបរឿងគោលោកមានរបួសនៅខ្នងដោយឈ្មោះវីណ្ណនាបានចោលត្រួវ ។

សេដ្ឋីខឹងណាស់ ត្រូវម្ដាយវ័ណ្ណនាជំពាក់បំណុលស្រាប់ផង លោកក៏ចាត់ខ្ញុំបំរើឱ្យទៅរឹបយកស្រែ យកផ្ទះនិងទ្រព្យសម្បត្តិអស់ គ្មានសល់ ឯរូបវ័ណ្ណនា សេដ្ឋីបង្គាប់ឱ្យទៅចាប់យកមកធ្វើទោស ។

ទឹកភ្នែកបានហូរជាជ្រោះ ជាស្នឹងនៅលើផ្ទៃភ័ក្ត្រម្ដាយ និង កូន ។

-ម៉ែ ! កូនមិនដឹងយ៉ាងណាទេ,,, ម៉ែ ! មើលអូនវ័ណ្ណនីផង ឱ្យនាងរក្សាត្រីប្រាំពណិនេះឱ្យគង់វង្ស,,,

មីងវ័ណ្ណ ឃើញគេចាប់កូនចងហៀបនឹងបណ្ដើរទៅ គាត់សម្រក់ជលនេត្រតបទៅបុត្រថា :

-សុំឱ្យទេវតាជួយកូនឱ្យរួចមកវិញ ម្ដាយមិនអាចឃ្លាតពីកូនបានទេ ជើងកូនឈានទៅឯណា ជំហានម្ដាយក៏ឈានទៅទីនោះដែរ !

-វ័ណ្ណនា,,, ឱ ! បង,,, (នាងវ័ណ្ណនីដួលសន្លប់នៅក្បែរម្ដាយ នាងស្រឡាញ់បងប្រុសនាង ហួសពីនាងស្រឡាញ់ជីវិតរបស់នាងទៅទៀត) ។

គេចងវ័ណ្ណនាក្រៀកទៅនឹងជញ្ជាំងរទេះគោ នាំចេញផុតពីផ្ទះកំសត់ទុគិតនេះទៅហើយ !

កាលខ្ញុំបំរើនាំបុរសកំសត់ទុគិតឡើងមកដល់គេហដ្ឋានសេដ្ឋី ហើយសេដ្ឋីក៏ចេញមក លោកអង្គុយកៅអីផ្ដៅមួយ បៀមខ្សៀនៅមាត់ ចងចិញ្ចើមដាក់អ្នកកម្លោះ លោកសួរថា :

-ម៉េចឯងហ៊ានចោលគោអញហ៎ ?

-បាទ,,, ទានប្រោស ! ខ្ញុំប្របាទគ្រាន់តែចោលដេញវាឱ្យខ្លាចប៉ុណ្ណោះ ព្រោះវាចូលស៊ីសំណាបខ្ញុំ,,, ខ្ញុំបាទពុំមានចេតនាចោលវាឱ្យមុតនោះឡើយ,,, ឥឡូវបើវាមានរបួសទៅហើយ សូមព្រះតេជគុណមេត្តាលើកលែងទោស ឱ្យទានខ្ញុំប្របាទម្ដងទៅ,,,

នាយទុន យកដៃច្បូតពុកមាត់បឹតខ្សៀ បញ្ចេញផ្សែងហុយទ្រលោម

សេដ្ឋីមិនទទួលអង្វរ ច្រឡោតខឹងយកតែពីឈ្នះដៃ :

-ឱ ! សំណាបអាឯងធំជាងគោអញឬ ? វ៉ឺយ ! ចងវាវាយ ១២០ រំពាត់ !

អ្នកដែលចាប់យុវជននេះមកមិនគឺអ្នកណាក្រៅពីខ្ញែក និង ស្នាំងឡើយ ហើយការសម្ងាត់អ្វីៗ អ្នកទាំងពីរនេះប្រាប់សេដ្ឋីយកគាប់គួរទាំងអស់

ខ្ញុំសេដ្ឋីទាំងពីរ ទាញរំពាត់សំពងវ័ណ្ណនាយ៉ាងសែនទារុណ ។

នរៈទុគិត ស្រែកថ្ងូរថា :

-អូយ ! លោកសេដ្ឋី,,, ប៉ុណ្ណឹងហើយ ទុកជីវិតឱ្យខ្ញុំឃើញមុខម្ដាយមុខប្អូនខ្ញុំផង,,,

-កុំស្ដាប់វា វាយថែមទៀត ! សេដ្ឋីបង្គាប់ ។

ផ្លែរំពាត់បង្ហូរជាភ្លៀងទៅលើសពាង្គកាយនរៈ ជាលើកទី ២ អ្នកទន់ខ្លួនបែកឈាមពេញអង្គប្រាណ អ្នកសន្លប់បាត់ស្មារតី,,, ។

ខណៈនោះមីងវ័ណ្ណនិងវ័ណ្ណនីឡើងទៅដល់ នាងកុមារីកាន់ក្រឡនៅដៃ ម្ដាយនិងកូនចូលទៅសំពះលោកសេដ្ឋី លោកសេដ្ឋីក្រោកឡើងកំហែងថា :

-មីសត្វនេះចេញពីផ្ទះអញឱ្យឆាប់ ហងឯងមិនចេះប្រដៅកូន អញអាណិត អញទុកដី ទុកផ្ទះឱ្យរកស៊ី វាហ៊ានចោលគោអញមុតចេញឈាមត្រូវតែអញវាយឱ្យបែកឈាមដូចគោវិញ,,, មីហងឯង មើលងាយអញណាស់ ! ទៅ ! ទៅឱ្យបាត់ពីមុខអញឱ្យឆាប់ !

-លោកសេដ្ឋី ! អាណិតកូនខ្ញុំទៅ,,,

វណ្ណនីហៀបនឹងយកត្រីប្រាំពណ៌ទៅជូនសេដ្ឋី ដើម្បីលោះបង តែនាងមិនហ៊ានទៅជិត នាងដាក់ក្រឡត្រីនៅក្បែរនោះយ៉ាងស្រួលរួច រត់មកឱបមាតា ។

ធ្លាប់តែចិត្តឆាវដូចភ្លើង សេដ្ឋីមិនដែលមានចិត្តមេត្តាទេ ។ លោកប្រើទាហានទាំងពីរឱ្យអូសស្រីម្តាយនិងកូនទម្លាក់ទៅដី នោះមីងវណ្ណនិងនាងវណ្ណនី ក៏ត្រូវខ្សែកនិងស្នាំងវាយដំច្រំធាក់ក្បាលនឹងជើង រមៀលតាមកាំជណ្តើរទៅដល់ដីបែកក្បាលហូរឈាមគួរឱ្យអាសូរពេក ។

ឱ ! ជីវិតអ្នកក្រ ! គ្នាក៏ជាមនុស្សដូចអ្នកមានដែរ គួរអ្វីសេដ្ឋីតិរច្ឆានប្រព្រឹត្តការជិះជាន់ ទុកគ្នាស្មើនឹងសត្វខ្លាំងម្លេះ ?

ទោះគេវាយទាំងម្លោះ មីងវណ្ណនិងនាងវណ្ណនី នៅតែទ្រាំងើបខំតោងជណ្តើរឡើងទៅលើផ្ទះសេដ្ឋី ទាល់តែបានម្តងទៀត ។

វណ្ណនាបានដឹងស្មារតីឡើងវិញ ឃើញម្តាយនិងប្អូនមានលោហិតប្រឡាក់ពេញមុខ អ្នកក៏ស្រែកសួរទៅអ្នកមានគុណនិងប្អូនអ្នកថា :

-ឱអ្នកម្តាយ ! អូនបង នរណាវាយឬ ?

កុមារីកំសត់អួលអាក់ក្នុងចិន្តា និយាយស្តីពុំរួច ។

នាងលើកក្រឡត្រីទៅជូនសេដ្ឋី ដោយវាចាគោរពថា :

-លោកសេដ្ឋីជាម្ចាស់លើជីវិតអ្នកក្រ ! សូមលោកលែងបងខ្ញុំទៅ ត្រីប្រាំពណ៌នេះ ខ្ញុំសូមជូនលោកទុកជាសម្បត្តិមានតម្លៃរបស់លោកម្ចាស់ទៅចុះ !

នៅជិតរាំងននខាងក្នុង កែវបុប្ផាឈរជើងមិននឹង ព្រោះនាងអាណិតមិត្តនាង អាណិតវណ្ណនី និងមីងវណ្ណស្ទើរតែរត់មកជួយ តែខ្លួនល្ងងមិនអាចធ្វើទៅបាន ។ នាងនឹកថា "រឿងនេះឆេះពីពូខ្មៅក និងពូស្នាំងប្រាកដ" ។

សេដ្ឋីមិនជឿថាត្រីនោះមានពណ៌ប្រាំយ៉ាងទេ លុះសង្កេតបន្តិចទៅលោកក៏ដឹងថាត្រីនោះល្អមែន ។

កែវបុប្ផាឃើញទឹកមុខឪពុកបែបស្រួល យល់ថាជាឱកាសល្អ នាងក៏ដើរចេញពីក្នុងមកលួងលោមផ្តមចិត្តបិតាថា :

-លោកប៉ា ! យកទៅ ត្រីនេះនរណាក៏គ្មានដែរ ទុកឱ្យខ្ញុំចិញ្ចឹម ! លោកប៉ាចាស់ហើយគួរលះបង់មិច្ឆាទិដ្ឋិនេះឱ្យស្រឡះទៅ លោកប៉ាកើតមានជាសេដ្ឋីនេះ មកពីអ្នកក្រឱ្យមាន ឥឡូវយើងមានហើយ ត្រូវយើងធ្វើពលីទានឱ្យអ្នកក្រខ្លះទៅ !

បុប្ផា និយាយនេះមិនមែនជាទីពេញចិត្តរបស់វណ្ណនាទេ អ្នកបែរយល់ខុសថា នាងនិយាយគ្រាន់អង្អែលខ្នងអ្នកឱ្យបាត់ខឹងប៉ុណ្ណោះ អ្នកចងគំនុំនឹងបុប្ផាយ៉ាងខ្លាំង...

ឮពាក្យដូច្នោះ សេដ្ឋីចង់កិននាងកំទេចម៉ាកទៀត តែលោកយល់ថាពាក្យនោះមិនមាននរណាចេះដល់ សមបុប្ផាចេះធ្វើឫកញ៉ុកញ៉ក់ច្បួតពុកចង្កាជូនលោកថែមទៀតនោះ លោកក៏ត្រឡប់ជាញញឹមមកកូនវិញ ។

លោកអោនថើបថ្ពាសបុត្រីផ្តមថា :

-ប៉ាអត់ទោសឱ្យកូនម្តង ថ្ងៃក្រោយកុំនិយាយស្តីប្រដៅឱ្យឪពុកដូច្នេះទៀត នៃកូន ! ការអ្វីៗត្រូវប្រាប់ប៉ាឱ្យដឹងមិនត្រូវលាក់ទេ ម្យ៉ាងទៀតផ្ទះអាអ្នកក្រ កូនមិនត្រូវឡើងលេងឡើយ !

មានប្រសាសន៍តែប៉ុណ្ណោះ លោកងាកទៅប្រាប់បាវឱ្យដោះលែងមនុស្សទោសចេញ ។

សេដ្ឋីពោលទៅកាន់មីងវណ្ណ និងកូនគាត់ទាំងពីរថា :

-អើ ! ទៅចុះ តែកុំទៅជាន់ទឹកដីរបស់អញទៀត ទៅ ! កុំមកឱ្យអញឃើញមុខទៀត !

ជីវិតទុគិតទាំងបីក៏សំពះសេដ្ឋីចុះមក ។ មកដល់ទ្វារមាត់ច្រក ម្ដាយនិងកូនឈរវ៉េវ៉ៃៗមិនដឹងជាតម្រង់ទៅខាងណា ទាល់តែអ្នកយាមទ្វារស្ទុះមករុញច្រានបណ្ដេញ ទើបរញ៉ីរញ៉ៃកាន់ដៃគ្នាឆ្ពោះមុខ ទៅទិសខាងត្បូង ។

មកដល់ទួលមួយ ឃើញគុហាចាស់មួយកន្លែង ក៏ឈប់សម្រាកកម្លាំងនៅទីនោះ ព្រោះមីងវ័ណ្ណដើរទៅមិនរួច ។

កម្លោះកំសត់លើកមាតាទៅផ្ដេកយ៉ាងស្រួល ។ ស្រីចាស់ទ្រមខ្លួនឈាមចេះតែហូរពីច្រមុះ ពីមាត់មិនឈប់ ។

គាត់និយាយខ្សាវៗ ទៅបុត្រពន្លកថា :

-វ័ណ្ណនា ! កូន,,, សេដ្ឋីចិត្តអាក្រក់ហួសពេកណាស់,,, មើលចុះគេវាយម្ដាយគ្រាំគ្រា ម្ដាយមិនមានជីវិតរក្សាអ្នកតទៅទៀតទេ អ្នកមើលថែទាំប្អូនឱ្យល្អផង,,, វ័ណ្ណនី !,,,

-ចា៎ះ ! ម៉ែកូននៅជិតម៉ែហើយ !

-វ័ណ្ណនី !,,, កូននៅតូចណាស់ !

-ម៉ែ ! ម៉ែ ! ស្លាប់ចោលកូនឬ ? កុមារីយំអួលអាក់ជាខ្លាំង ។

អានិសង្សមីងវ័ណ្ណកសាងពីបុព្វជាតិបានមកតែប៉ុណ្ណោះ គាត់ដកចង្កាមាន់ ង៉ឺត ! ង៉ឺត ! បញ្ចភាពក្នុងខ្លួនរលត់អស់ ធាតុត្រជាក់មកជំនួសវិញ ។

ព្រះសុរិយាបញ្ចប់ព្រះសូរ្យសែង មីងវ័ណ្ណក៏បញ្ចប់ដំណើរជីវិតរបស់គាត់ត្រឹមនោះដែរ ។

ឱ ! ពុទ្ធោ ! សេដ្ឋីមិនមែនចិត្តអាក្រក់ ចិត្តខ្មៅប៉ុន្មានទេ មានមច្ចុរាជចិត្តខ្មៅលើសពីនេះទៅទៀត មច្ចុរាជហូតជីពជន្មស្រីមេម៉ាយ ដោយឥតអាណិតអាសូរក្មេងកំព្រា បងប្អូននេះដ៏តិចតួចសោះ ។

វ័ណ្ណនា និងវណ្ណនី ឱបសពមាតាយំលាន់ឮខ្ទរពេញទិសទី ។

-បងវណ្ណនា, វណ្ណនីយំផងនិយាយផង ។ យើងកំព្រាហើយ យើងគិតយកម៉ែទៅទុកដាក់យ៉ាងដូចម្ដេច ? យើងតែពីរនាក់យ៉ាងនេះ ! បងឱ្យខ្ញុំទៅផ្ទះសេដ្ឋីទៅ ក្រែងសុំប្រាក់លោកបានខ្លះ,,,

-ទេ ! ទេ ! អូន ! យើងស៊ូស្លាប់ទាំងអស់គ្នា ជាជាងពឹងបុណ្យសេដ្ឋី,,, ហ៊ុះ ! កែវបុប្ផ,,, វ័ណ្ណនី ! បងគិតទៅពឹងអ្នកក្រដូចគ្នាវិញ បងប្អូនជិតខាងយើងបើដឹងមុខជាជួយយើងមិនខាន តែយើងទៅឯណាបាន បើសេដ្ឋីហាមមិនឱ្យយើងទៅជាន់ដីត្រង់នោះសោះនោះ ?

កំពុងប្រឹក្សានឹងគ្នាដូច្នោះ ស្រាប់តែសម្លេងមួយបន្លឺមកថា :

-បងវ័ណ្ណនា ! អូនវ័ណ្ណនី,,,

សម្លេងហៅនេះ បានមកកញ្ឆក់ស្រូបយកព្រលឹងបងប្អូនទាំងពីរឱ្យភាន់ភាំងស្មារតី ។

គឺនាងកែវបុប្ផ ។ នាងដណ្ដប់ក្រមាដើរចូលមក មានអាការភិតភ័យកញ្ឆោងាកមើលទៅក្រោយម្ដងៗ ។

បុប្ផនឹកស្មានវ័ណ្ណនាទទួលនាង ដោយសោមនស្សហើយ តែមិនដូច្នោះអ្នកកម្លោះនេះបែរជាស្ទុះមកចាប់គ្រញិចនាង ផ្ទប់ទៅនឹងជញ្ជាំងគុហា ។

នារីញ័រមាត់ញ័រក ព្រោះវ័ណ្ណនាមិនដែលប្រព្រឹត្តអាការឃោរឃៅមករកនាងដូច្នេះសោះ ។

អ្នកកម្លោះឆ្លតដោយទោសៈ ស្រដីទៅនាងថា :

-បុប្ផ ! នាងមកធ្វើអីទីនេះ ? ម្ដាយយើងអនិច្ចកម្មទៅហើយ នាងជាស្រីចាក់រុកឱ្យឪពុកនាងធ្វើបាបយើង !

កល្យាណីស្លុតបំពង់ក ឆ្លើយទៅប្រុសសង្សារថា :

-បងវ័ណ្ណា,,, ស្ដាប់ប្អូនសិន ប្អូនមកនេះ គឺយកជីវិតមកផ្ញើលើបង និងជំរាបបងនូវការស្មោះត្រង់របស់ប្អូន គឺខ្ញែកនិងស្ទាំងទេតើជាអ្នកប្ដឹងលោកប៉ានោះ ខ្ញុំអាណិតបង ! អាណិតអ្នកមីងនិងអូន វ័ណ្ណនីជាទីបំផុត ! ឱ !,,, មីងកំសត់ វាសនាមីងអីក៏អាក្រក់ម្ល៉េះ ?

មាណវីស្ទុះទៅជិតសពមីងវ័ណ្ណ នាងយំ នាងសោកសង្រេង បន្ទោជលនេត្រឥតខ្មាសអៀន ហាក់ដូចនាងជាសមាជិកាមួយរូបនៃសពអនាថានេះដែរ ។

ទោសៈមោហៈ ដែលដុតកំដៅក្នុងទ្រូងវ័ណ្ណនាទាំងប៉ុន្មាន បានទ្រោមទ្រុឌរលត់ស្ងប់ស្ងាត់ទៅវិញអស់ ។

-បុប្ផអូន ! បងសូមហៅអូនឱ្យពេញមាត់ទៅចុះ បងមិនដឹងអូនចិត្តស្មោះត្រង់នឹងបងដូច្នេះទេ,,,

កម្លោះដើរទៅជិតនាង ឈ្ងោកមុខទៅក្បែរសក់នាង សក់នោះចោលក្លិនក្រអូបដល់នាសាអ្នក ។

មាណពបន្តពាក្យថា :

-បុប្ផ,,, អូនឃើញជាក់នឹងភ្នែកហើយ អំពើឧក្រិដ្ឋរបស់ឪពុក អូនអាចធ្វើឱ្យបងស្អប់អូនទៀត តែពេលនេះអូនបានបញ្ចេញភស្ដុតាងនៃសមានចិត្តរបស់អូន ឱ្យបងឃើញប្រាកដ បងសូមផ្ញើសេចក្ដីស្នេហារបស់បងលើអូនបានទេ ?

-បងវ័ណ្ណា ! ទឹកចិត្តដែលប្អូនបានបង្ហូរជាជ្រោះទឹកភ្នែកយ៉ាងនេះ បងមិនជ្រាបទេឬ ? ត្រូវជ្រាបថាពីពេលនេះទៅ ដរាបណាប្អូនមិនបានបងជាគូជីវិតទេ ដរាបនោះប្អូនស៊ូតែស្លាប់មួយមុខប៉ុណ្ណោះ ចំពោះសពអ្នកមីងនេះ ចាំខ្ញុំឱ្យប្រាក់បងធ្វើបុណ្យទាំងអស់ បងកុំព្រួយបារម្ភអ្វីឡើយ !

ខណៈគូស្នេហាទាំងទ្វេហារកំពុងប្ដូរមធុរសកថាគ្នានេះ វ័ណ្ណនី មិនបានយកភ្នែកមើលទេ នាងរវល់តែយំឱបសពមាតា អួលអាក់ក្នុងចិន្តាក្រៃលែង ។

ដោយសក់បុប្ផចេះតែឱ្យក្លិនឆ្ងាញ់ពិសា មានគន្ធរសជានិរន្ត នោះអ្នកកម្លោះក៏សួរនាងថា :

-ចុះអូនបានអ្វីលាបសក់ក៏ក្រអូបម្ល៉េះ ?

-ជំរាបអ្នកបង សក់បូនក្រអូបតាំងពីកំណើតមក !

-ពិតមែនឬអូន ?

-ខ្ញុំមិនចេះនិយាយភូតកុហកទេ !

-អូនឱ្យបងថើបសក់នេះល្បងមើលបានទេ ?

មិនបាច់ស្រីឆ្លើយឡើយ កម្លោះថើបសក់ រួចថើបដល់ថ្ពាល់យ៉ាងក្រហមរលោងរបស់នាងទៀត ។ អ្នកលូកដៃទៅប៉ះលើថនាទាំងគូដែលនៅក្រពុំបរិសុទ្ធ មានទឹកដមភ្លឺចាំងដល់បេះដូងយុវជនយើង សោតឯកញ្ញាក៏កើតមនោសញ្ចេតនាព្រឺព្រួចស្នេហាពន់ប្រមាណ ។

អ្នកទាំងពីរកំពុងផ្ដោតសរសៃវិញ្ញាណ ទាក់ទងគ្នាដោយហត្ថារូបរីតនោះ ស្រាប់តែមានសម្លេងគ្រលរមួយកំហែងភ្លាមឡើងថា :

-កែវបុប្ផ ! អូយ,,, កូនស្រីឪពុក នេះហៅចំជាកូនស្រីចេះរកប្ដីខ្លួនឯង កូនមកជួបអាកំពូជអ្នកក្រនេះទៀត តើកូនចង់យកវាជាប្ដី ឬ ?

លោកសេដ្ឋីនិងបាវទាំងពីរ ឈរកាន់អាវុធនៅមាត់គុហា ។ វិណ្ណនានិងបុប្ផារបូតដៃឃ្លាតឆ្ងាយពីគ្នា ។ យុវតីរន្ធត់អស់អង្គអាត្មា វិណ្ណនាតាំងជំហរប្រុងខ្លួន វិណ្ណនីក្រោកទៅរកទីកំបាំងខ្លួន នាងមានទឹកមុខស្លេកស្លាំងរកអ្វីប្រៀបពុំបាន ។

បុរសចិត្តអប្រិយ៍បង្គាប់ទៅខ្ញុំបំរើម្នាក់ថា :

-អាខ្មៅក ! ចាប់បុប្ផានាំទៅផ្ទះ ឯអាប្រុសនេះទុកឱ្យអញនិងអាស្ទាំងសម្លាប់វាចោលឥឡូវនេះ !

សេដ្ឋីចោលភ្នែកឃើញសពមីងវិណ្ណ លោកដើរទៅយកជើងឈ្លូសក្បាលបុគ្គល រួចពោលថា :

-កន្លែងនេះជាដីរបស់អញ វាមកស្លាប់លើដីអញ មីចោរ ចង្រៃ!

វិណ្ណនាស្ទើរតែហក់ទៅហុតឈាមសេដ្ឋី កុំឱ្យសល់មួយដំណក់ដល់ដីតែរកឱកាសមិនបាន ។

ខ្មៅកប្រអូសប្រទាញយកកែវបុប្ផាបាត់ទៅហើយ !

ស្ទាំងហូតដាវ ! សេដ្ឋីហូតដាវដែរ គាត់ឈរឃាំងផ្លូវ វិណ្ណនា ដៃទទេ វិណ្ណនីភ័យពេកទៅជាអង្គុយដូចរូបចម្លាក់ ។

ស្ទាំងលោអាវុធដេញកាប់ជនកំសត់ ជនកំសត់គេចយ៉ាងរហ័ស ផ្លែដាវហើរវឹត១ក្បែរខ្លួនអ្នក គួរឱ្យប្រហោងពោះជាទីបំផុត ។

លុះស្ទាំងផ្លាតជើងដួល អ្នកក្លាហានយើងក៏លោតទៅធាក់និង វាយវារហូតយកអាវុធបាន ។ នាយទាសាត្រូវប៉ុន្មានដៃធ្ងន់១ ងើបមិនរួចក៏រលត់បាត់ស្មារតីទៅ ។

តាកញ្ជាស់ធ្វើគ្រាន់បើ លើកដាវមិនរួចស្ទុះមកកាប់វិណ្ណនាទាំងត្រដរ ។ យុវជនមិនទាន់ប្រឹងផង គ្រាន់តែញលដាវតែបន្តិច ដាវសេដ្ឋី ក៏ធ្លាក់ខ្ទក លោកធ្វើភ្នែកដូចភ្នែកត្រីស្ងោរ ។ កម្លោះយកចុងអាវុធ ទល់ពោះលោក លោកដើរថយក្រោយបែបភ្ញាក់១,,,

-លោកសេដ្ឋី ! ជីវិតលោកនៅក្នុងកណ្ដាប់ដៃខ្ញុំហើយ ឥឡូវ លោកចង់ស្លាប់ឬចង់រស់ ?

តាចាស់រកទឹកមាត់លេបគ្មាន ក៏ឆ្លើយញ័រមាត់ញ័រកថា :

-អ្នកក្លួយ អឺះ,,, កុំ ! កុំ ! ហ៊ឺ ! កុំលេងរបៀបហ្នឹង,,,

-មិនទាន់ឈឺសាច់ផង ម្ដេចក៏ប្រញាប់ស្រែកម្ល៉េះ ? ខ្ញុំស្មានថា អ្នកមានមិនចេះភ័យទេ ហើយអ្នកមានប្រហែលជាស្បែកក្រាស់គ្រាន់បើ បើកាប់មួយដាវមិនមុតទេ !

-ទេ ! ទេ ! ក្មួយអើយ,,, ស្បែកអ៊ំផុយណាស់,,, កុំរុញចុងដាវមកទៀត ចង់បានអ្វីអ៊ំឱ្យ កុំតែសម្លាប់មួយមុខប៉ុណ្ណោះ !

-ខ្ញុំមិនចង់បានអ្វីក្រៅឱ្យពីលោកសេដ្ឋី ថ្វាយបង្គំសពម្ដាយខ្ញុំបីដងយ៉ាងគោរពនោះទេ !

សេដ្ឋីច្រឡោតខឹងក្ដួង គំហកថា :

-ចឹ ! អាអ្នកក្រ ! អញមិនដែលទៅថ្វាយបង្គំមនុស្សបែបម៉ែអាឯងនេះទេ,,, អូយ ! ហ៊ឺ ! លោកអើយ !

វិណ្ណនាកាប់ជើងសេដ្ឋីមួយដាវយ៉ាងធ្ងន់ ឈាមហូរជោគដី មាណពត្មះតិះដៀលទៅសត្រូវរបស់អ្នកថា :

-ជើងនេះវាព្រហើនជាន់ក្បាលមនុស្សរស់ រហូតដល់មនុស្សស្លាប់ទៀត បានជាខ្ញុំកាប់ បើលោកមិនព្រមសំពះម្ដាយខ្ញុំទេ ខ្ញុំនឹងកាប់ជើងម្ខាងទៀត ។

-ដល់ថ្នាក់នេះ សេដ្ឋីលុតក្រាបៗញាប់ស្អេក លើសពីរបីដងទៅទៀត ។

-ទាល់តែដាក់ថ្នាំខ្លាំង ទើបលោកសំពះ បើសំពះពីនាយមកប្រហែលជាស្រួលខ្លួនជាង !

ទីបំផុត កម្លោះដាល់បិតាបុប្ផាមួយដៃផ្ទប់ទៅជញ្ជាំង ។ លោកងងឹតមុខសន្លប់បាត់ស្មារតីតែម្ដងទៅ ។ វិណ្ណនីខណៈនោះ រត់មកកាន់ដៃបង ហត្ថានាងមានសភាពញ័រជាដរាប ។

ចៅកំសត់ប្រាប់ប្អូនស្រីថា :

-វិណ្ណនី ! យើងនៅទីនេះមិនបានទេ យើងត្រូវលីម្ដាយយើងរត់ទៅមុខទៀត,,,

មាណពលើកសពមាតាដំកល់លើស្មា អាវុធសៀតនៅចង្កេះជាប់ ដៃអ្នកខាងឆ្វេងដឹកដៃប្អូនតូច ដៃស្ដាំកាន់ទប់ជើងមាតា ជើងទាំងពីរឃ្មាតខ្មីរត់ចេញពីគុហា ។

វិណ្ណនាគ្រោះល្អ គ្រាន់តែចេញផុតភ្លាម ពួកពលសេដ្ឋីមកដល់ល្មមឆោឡោនឹងឃើញសេដ្ឋីត្រូវរបួសដួលសន្លប់នៅនោះ ។

## ៥
## គូរួមជីវិត

ខណៈនោះ ខ្មែកដែលបានចាប់កែវបុប្ផាទៅទុកឯផ្ទះ បានត្រឡប់មកវិញ ជាមួយមនុស្សប្រាំបីនាក់ ។ អ្នកទាំងនេះ ខ្លះចូលទៅលើកលោកសេដ្ឋីខ្លះសាកសួរស្មាំងនូវហេតុផ្សេងៗ ។ ស្មាំងនេះក៏ទ្រមណាស់ដែរ និយាយស្ទើរមិនចង់ចេញ ។

សេដ្ឋីដឹងខ្លួនហើយ ក៏បង្គាប់ទាសាប៉ុន្មាននាក់នោះថា :

-ពួកឯងដេញចាប់វាឱ្យបាន !

ក្រុមជំនិតសេដ្ឋីប្រដាប់ដោយអាវុធគ្រប់ដៃ ក៏ឡើងសេះបរគគ្រឹកគគ្រេងទ្រហឹងអឹងកង ដេញតាមមួយរំពេច ។

វិណ្ណនា ហេតុតែមានកតញ្ញូកតវេទិចំពោះមាតា អ្នកក៏មិនច្បុតឡើយ ពួកអ្នកប្រាថ្នាជីវិតអ្នក ក៏ជ្រួសផ្លូវរកដានអ្នកមិនឃើញ ។ អ្នកសំងំពួនក្នុងព្រៃជាមួយសពម្ដាយ និងជាមួយនាងវិណ្ណនី ។

ដល់វេលាយប់ ទើបអ្នកចរចេញទៅរកមិត្តដែលនៅជិតផ្ទះអ្នកឯមាត់ស្ទឹង ។ មិត្តជាច្រើនបានមកជួយយកសពមីងវិណ្ណ ត្រឡប់ទៅកាន់ទីលំនៅពួកខ្លួន ហើយក៏ធ្វើក្ការមឈូស បញ្ចុះសពតាមប្រពៃណី ។ គេអាណិតមីងវិណ្ណគ្រប់ៗគ្នា ហើយគេបានជួយចិញ្ចឹមវិណ្ណនីទុកដូចជាកូនគេបង្កើត ។ ឯវិណ្ណនា អ្នកមិនហ៊ាននៅស្រុកទេ ព្រោះខ្លាចសេដ្ឋីតាមព្យាបាទ ។

វិណ្ណនាដើរផ្សងព្រេងម្នាក់ឯង ទៅនៅឯភ្នំដងរែក ជីវិតអ្នក វិស័យដូចចករសាត់តាមខ្សែទឹកហូរ ។

ចំណែកកែវបុប្ផា នាងមិនស្គាល់អ្វីដែលហៅថាសប្បាយម្ដងទេ វិប្បយោគទុក្ខតែងប្រឆាំងក្នុងដួងចិត្តរបស់នាងជាដរាប ។ កញ្ញាខឹងនឹងឪពុកណាស់ សូម្បីលោកមានរបួសដើរមិនរួចដូច្នោះក៏ដោយ ក៏នាងមិនសួរយកចិត្តទុកដាក់ប៉ុន្មានឡើយ ។ ដួងព្រលឹងនាងដកថយចេញពីស្រមោលស្នេហ៍ពុំបាន ។ ធីតាមានជីវិតក្រៀមក្រំស្រពាប់ស្រពោនដូចរុក្ខជាតិខ្វះទឹកភ្លៀង ។ ប៉ុន្តែបុប្ផា បើបានទៅប្រឡែងលេង នឹងត្រីប្រាំពណ៌ក្នុងកែវវិចិត្ររបស់នាង

វេលាណា វេលានោះទម្ងន់ទុក្ខទាំងប៉ុន្មានក៏រសាយអស់ ។ ត្រីប្រាំពណ៌ គឺជាតន្ត្រីវិសេសសម្រាប់រម្ងាប់អារម្មណ៍របស់កល្យាណី ។

មានម្តង មាណវី ឈ្ងោកមុខទៅក្នុងកែវត្រី នាងស្រមៃឃើញប្រុសកំសត់របស់នាងនៅនោះ ។

-វណ្ណា ! បង ! បង !,,,

បុប្ផាស្រែកហៅដោយរលឹកគេខ្លាំងពេក ។

យូរថ្ងៃកន្លងមកលោកសេដ្ឋីជាដើង ដើរទៅណាមកណាបានដូចប្រក្រតី ។ ឯបុប្ផា ជម្ងឺរលឹកសង្សាររបស់នាងមិនព្រមសះស្បើយឡើយ វាធ្វើឱ្យនាងឈឺចុកចាប់សព្វទិនទិវារាត្រី ។

មានយប់មួយ ស្រីបណ្តូលស្នេហ៍របស់វណ្ណា គេងលក់នៅក្នុងដំណេក ។ នាងយល់សុបិន្តឃើញត្រីប្រាំពណ៌មកប្រាប់នាងថា :

-ម្ចាស់កុំកើតទុក្ខ គូម្ចាស់សព្វថ្ងៃទៅដើរសំពៅក្នុងសមុទ្រស្រុកសៀម បើម្ចាស់នឹងទៅរក នឹងជួបជាមិនខាន,,, ឯរូបខ្ញុំនេះ ម្ចាស់កុំទុកខ្ញុំក្នុងកែវតទៅទៀត ស្អែកនេះខ្ញុំស្លាប់ហើយ ម្ចាស់យកខ្ញុំទៅចំអិនបរិភោគចុះនោះរូបម្ចាស់នឹងក្លាយទៅជាមានពណ៌ប្រាំយ៉ាងជាបញ្ចពណ៌នារីល្អផុតស្រីក្នុងកម្ពុជាល្បីពេញទ្វីបលោក !

កែវបុប្ផា ភ្ញាក់ឡើង ពន្លឺអរុណដាលដាសពាសពេញបន្ទប់នាងស្រេច ។ នាងមានចិត្តកន្ទះរា ជឿបន្តិចមិនជឿបន្តិច ។ លុះនាងទៅឈ្ងោកមើលត្រីត្រីនោះស្លាប់មែន យុវតីអរផងភ័យផង នាងពុំអាច យករឿងនេះទៅប្រាប់នរណាឱ្យដឹងឡើយ សូម្បីបិតានាង ក៏នាងមិនប្រាប់ដែរ ។

នាងសក់ក្រអូបចំអិនត្រីប្រាំពណ៌ បរិភោគតាមពាក្យត្រីប្រាប់ពីយប់មិញ ។ ប្រាកដណាស់ អស្ចារ្យណាស់ រូបបុប្ផាកាន់តែមានពណ៌ប្លែកសាច់នាងខ្ចីសស្អាតដូចទិព្វនារី គឺជាបវរកញ្ញាមួយរូបរកស្រីក្នុងលោកមកប្រដូចមិនបាន ។

លោកសេដ្ឋីស្ទើរមើលកូនមិនស្គាល់ ។ កាលឃើញបុប្ផាមានរូបសម្បត្តិចំឡែកប្លែកអស្ចារ្យដូច្នោះ ក៏សាកសួរជាការសម្ងាត់ ។ នាងប្រាប់បិតាតាមរឿង ។

លោកមានបីតិសប្បាយរីករាយជាអនេកប្បការ នឹកថាកូនអញនឹងបានទៅជាអគ្គមហេសីនៃព្រះចមពល ដ៏មានអានុភាពធំលើសលែងក្នុងលោកណាមួយមិនខាន ។

ក្នុងមួយថ្ងៃនាងក្រមុំផ្លាស់ពណ៌សម្បុរប្រាំយ៉ាងដូចត្រីដែរ ទើបសេដ្ឋីដាក់ឈ្មោះនាងថា "នាងកែវបញ្ចពណ៌ " ឯអ្នកស្រុកដែលធ្លាប់ដឹងថា នាងមានសក់ក្រអូបពីកំណើតមក ក៏និយមហៅថា "នាងសក់ ក្រអូប" ទៅ ។

រូបឆោមលោមពណ៌កែវបញ្ចពណ៌ ក៏អណ្តែតសព្វទិសានុទិសក្នុងកម្ពុជ្ជ ទាំងមន្ត្រី ទាំងរាស្ត្រ ទាំងស្តេចមកចោមរោមស្ដីដណ្តឹងធីតារាល់ថ្ងៃ ។

ផ្ទះលោកសេដ្ឋីដែលធ្លាប់តែស្ងាត់ ឥឡូវក៏ក្លាយទៅជាទីប្រជុំជន មានមនុស្សកុះករអ៊ូអរជាអចិន្ត្រៃយ៍ ខ្លះកាត់មកពីស្រុកជិត ខ្លះកាត់មកពីស្រុកឆ្ងាយ ។ ពួកទាំងនេះ មិនទាន់បានឃើញរូបនាងកែវបញ្ចពណ៌យ៉ាងណាផងក៏សន្និដ្ឋានគ្រប់ៗគ្នាថា នាងជាប្រពន្ធរបស់ខ្លួនរួចទៅហើយ ។

ការវិវាទក៏ផ្ទុះឡើងចំកណ្តាលផ្ទះសេដ្ឋី គេវាយកាប់សម្លាប់គ្នា ព្រោះតែស្រីម្នាក់ ផ្ទះយ៉ាងធំ ជណ្តើរយ៉ាងមាំ ក៏ទប់មិនឈ្នះនឹងទម្ងន់មនុស្ស ។

គេហជនអស់សប្បាយទៅជាភ័យ អស់ដាក់ស្លាដាក់បារីជូន ភ្ញៀវទៅជាលើកដំបង លើកអំបោសដេញភ្ញៀវឱ្យចុះពីផ្ទះខ្លួន ។

សេដ្ឋីចាញ់ចំណេះឃាត់ភ្ញៀវមិនស្ដាប់ ក៏ខ្សឹបប្រាប់កែវបុប្ផាឱ្យដោះខ្លួនរត់ នោះធីតាក៏គេចខ្លួនពួនអាត្មាចេញតាមទ្វារក្រោយរត់ទៅជ្រកនៅក្នុងព្រៃជាមួយខ្មៅកនិងស្វាំង ។

ឯសេដ្ឋីក៏បានឱកាសរត់ដែរ ចុះតែខោនិងអាវមួយសម្រាប់ប៉ុណ្ណោះទៅជួបនឹងកូន ។

ពួកដែលទៅចោមដណ្ដឹងនាងកែវបញ្ចពណ៌ទាំងប៉ុន្មាន ស្មាននាងពួនក្នុងផ្ទះ ក៏បបួលគ្នាឆែករឆ្កែកកាយ កាលបើរកនាងមិនឃើញ បាត់ទាំងខ្លួនសេដ្ឋីទៀត ពួកនោះខឹងខ្លាំង ក៏កាប់បំផ្លាញដុតផ្ទះសេដ្ឋី ទាល់តែខ្ទេចល្អិតម៉ដ្ឋទៅជាផេះ ។

ភូមិឋានសេដ្ឋី ប្រែក្លាយទៅជាទីវាលមួយគួរឱ្យខ្លាច ។ ឱ ! សេដ្ឋីចុះក្រហើយ ! ផ្ទះមានកូនក្រមុំល្អ គឺជាផ្ទះមានខ្មាំងសត្រូវ !

ពេលដែលលំនៅលោកគហបតី បានត្រូវព្រះអគ្គីភ័យសោយអស់ទៅហើយ ព្រះកុមេរុរាជ គឺព្រះថោង ព្រះចៅក្រុងកម្ពុជាធិបតី ស្ដេចលើកយោធាមកដណ្ដឹងកែវបុប្ផាដែរ ទ្រង់ចងព្រះទ័យស្នេហាលើនារីនេះណាស់ ថ្វីដ្បិតតែទ្រង់មិនបានទតឃើញរូបឆោមនាងដល់ម្ដងសោះ ។ ស្ដេចចាត់ឧកញ៉ាពិជ័យសង្គ្រាមឱ្យលើកកងយោធាតាមដាន នាងកែវបញ្ចពណ៌ភ្លាម ឯព្រះអង្គទ្រង់យាងចូលរាជវាំងវិញ ។

រីឯសេដ្ឋីនិងបុត្រីលោក ពួកងទ័ពព្រះថោងដេញតាមរកថែមទៀតនោះ ក៏រីងរីតតែរួញប្រមាត់ រួញថ្លើមឈរនៅលើដីស្ទើរតែមិនជាប់ ។ បុប្ផានាំឪពុក និងទាសាទាំងពីរដើរកាត់ព្រៃផ្សែកណ្ដែងកណ្ដោចអរណ្យភូមិតម្រង់ភ្នំដងរែក ដើម្បីស្វែងរកវិណ្ណនាគូសង្សាររបស់នាង ។

មកដល់ទីស្មសានមួយ ដាច់ស្បៀងអាហារ គ្រប់អាត្មាសឹងសុទ្ធស្រេកឃ្លានមានមុខក្រៀមស្រពោនខ្មៅអែ ។

បុរសឪពុកធ្លាក់ក្នុងទុព្វលភាពយ៉ាប់យ៉ឺនជាខ្លាំង ដេកស្ដូកលើពសុធា បុប្ផានិយាយថា :

-លោកប៉ា ! កាលពីដើមលោកប៉ាជេរត្មះតិះដៀលបងវិណ្ណនា ថាគ្នាជាពូជអ្នកក្រ លោកប៉ាធ្វើបាបអ្នកក្រ មើលងាយជិះជាន់អ្នកក្រ ឥឡូវដល់ថ្នាក់យើងក្រម្ដង ក្របែបយើងនេះគ្មាននរណាមើលមុខទេ !

-បុប្ផាកូនស្រី ! ប៉ាមិនដែលប្រទះការលំបាកដូច្នេះសោះ !

ខ្មៅកនិងស្វាំងអស់កម្លាំងដែរ រលំគ្រេងដូចគោចាស់ ។

នាងកែវបញ្ចពណ៌តប់ប្រមល់ទាល់ពុទ្ធោ ល្ហិតល្ហៃក្នុងចិត្តដូចនៅកណ្ដាលសមុទ្រ ។ នាងឈានជើងដើរទៅមុខបន្តិច ក្រែងឃើញផ្ទះគេ ឬជួបអ្នកដំណើរ នាងនឹងសុំបាយទឹកគេយកមកបរិភោគ និង ជូនឪពុកកែវវរលក្ខណ៍ មិនជួបប្រទះនរណាម្នាក់សោះ ឮសូរតែសម្លេងសត្វយំ និងសូរខ្យល់ប្រទ្បែងលើស្លឹកឈើ ។ កញ្ញាផុតសេចក្ដីសង្ឃឹម ដើរមកអង្គុយសំកុកជិតឪពុក នាងយំខ្សឹកខ្សួលអួលអាក់ហួសប្រមាណ ។

លុះសម្រាកមានកម្លាំងបន្តិច សេដ្ឋីក៏បន្តផ្លូវទៅទៀត ។ ជីវិតទាំងបួនធ្វើដំណើរយូរថ្ងៃទាំងស៊ីអត់ស៊ីឃ្លាន ទាល់តែមកដល់ឆ្នេរសមុទ្រតាមជួរភ្នំដ៏ធំៗទើបឈប់នៅទីនោះ ។

ព្រះសូរ្យសែងចាំងរស្មី គ្របដណ្ដប់ទៅលើសំពៅមួយ ដែលចតនៅនាឆ្នេរជលសានោះ ។ ពួកនាវិកទាំងប៉ុន្មានក្រឡេកឃើញអ្នកដំណើរបួននាក់នាំគ្នាដើរត្រសងតម្រង់មកក៏ឆ្លេឆ្លាបាញ់ចក្ខុសង្កត់ទៅលើរូបនាងកែវបុប្ផាដែលជាវិការដ្ឋានចំឡែកមិនដែលឃើញ ។

គេដាក់ស្ពានឱ្យបុរសស្រីមកពីចម្ងាយ ឡើងមកលើនាវាគេ ឈរព័ទ្ធជុំវិញ កញ្ញានិងសហជីវិននាងទាំងបីប្រាណ ។ យើងបានសំដែងអាការៈគោរពដល់ពួកដើរសមុទ្រទាំងនោះ ។

ជាបឋម បុប្ផាបានហាមាត់យ៉ាងស្រស់ក្រហម ជម្រុះវាចាផ្អែមពិរោះថា :

-លោកអ្នកសប្បុរស ! សូមលោកចែកស្បៀងអាហារដល់យើងបន្តិចបន្តួចតាមកម្លាំងសទ្ធា,,, យើងទាំងបួននាក់នេះដាច់បាយមកច្រើនថ្ងៃហើយ !

នារិកទាំងឡាយស្រាប់តែសើចគិលឡើង ហើយម្នាក់ៗក៏ស្ទុះទៅចាប់ឱបនាង នាងភ័យណាស់ខំដោះខ្លួនរត់ តែរត់មិនផុតពីកណ្ដាប់ដៃពួកមនុស្សសាមាន្យឡើយ ។

ពួកនេះ ដណ្ដើមស្រីដូចមនុស្សអត់ឃ្លានដុនដាបបង្កើតជាការជម្លោះវាយដាល់តប់គ្នាយ៉ាងសម្បើម ផ្អើលដល់នាយភេត្រាជាម្ចាស់សំពៅនៅខាងក្នុង ។

ចៅកែចេញមក ។ លោកជាយុវជនមួយរូប ដែលយើងធ្លាប់ស្គាល់ឈ្មោះ ធ្លាប់ស្គាល់មុខមកហើយ !

ក្រឡេកឃើញកែវបុប្ផា នៅក្នុងកណ្ដាប់ដៃកូនចោរម្នាក់ លោក មេទ័ពក៏ស្ទុះទៅដាល់វាមួយដៃផ្ងួងធ្លាក់ទឹកគ្រាំ ។ លោកដណ្ដើមយកនាងបានកល្យាណីស្គាល់អ្នកការពារនាង នាងត្រេកអរហួសព្រំដែន នាងឱបចៅកែយ៉ាងខ្ជាប់ រួចបង្ហូរពាក្យទាំងជលនេត្រថា :

-បងវិណ្ណនា ! ឱ ! ប្រុសជីវិតប្អូន !,,,

-បុប្ផាអូន !,,, យើងបែកគ្នា ៨ ខែហើយមែនទេ ?

-មិនមែន ៨ ខែទេបង គឺ ៨ ខែ ១០ ថ្ងៃ !

-យី ! អូនចាំមែន អូនរាប់រាល់ថ្ងៃឬ ដែលបងឃ្លាតមក ?

-ចា៎ះបង ! បង ! ប្អូនរលឹកបងណាស់ !

-បុប្ផា ! ម្ដេចប្អូនរសាត់មកទីនេះដែរ អូនល្អជាងមុនឆ្ងាយណាស់ (លោកទៅថើបសក់នាង) សក់អូននៅក្រអូបដដែល បងមិនភ្លេចក្លិនអូនទេ !

ពួកនៅក្រោមបង្គាប់វិណ្ណនា ឃើញដូច្នោះក៏ឈរស្រឡាំងកាំង ព្រោះមិនដឹងបុប្ផាជាគូសង្សាររបស់ចៅហ្វាយនាយខ្លួន ។

យុវតីចង្អុលទៅលោកសេដ្ឋី នាយខ្វែកនិងនាយស្ទាំង ដែលឈរឆ្ងាយពីគេនៅឯក្បាលសំពៅ ដោយវាចាថា :

-វិណ្ណនា ! នុ៎ះ ! លោកប៉ានិងបាវជំនិតខ្ញុំទាំងពីរ ម្ដេចបងមិនមើលគាត់ផង ?

-ឯណាអូន ? លោកសេដ្ឋីមកដែរ ?

-មិនមែនលោកសេដ្ឋីទេបង ! គឺលោកឪពុកខ្ញុំ !

វិណ្ណនាធ្វើមុខឆ្ងល់ ស្ទុះទៅជិតបុរសទាំងបីនាក់ ។ អ្នកមើលសេដ្ឋីមិនស្គាល់ ព្រោះគាត់មានទឹកមុខខ្មៅជាំ រាងស្គម ពុកមាត់ស្រមូម ខោអាវប្រឡាក់ស្រមកប្រឡេសប្រឡូសដូចកម្មកររែកដី ។

កម្លោះចិត្តទេវតា មិនប្រកាន់ខឹង ក៏ចូលទៅសំពះលោកយ៉ាងគោរពហើយសួរថា :

-លោកអ៊ំ ? សុំអត់ទោសឱ្យខ្ញុំផង ព្រោះខ្ញុំមើលមិនស្គាល់ !

សេដ្ឋីឆ្លើយទាំងរអាក់រអួលថា :

-អ្នកត្រូវលុបលាងទោសឱ្យផង ព្រះអាទិត្យបានបំភ្លឺផ្លូវឱ្យយើងបានមកជួបគ្នាដូចសេចក្ដីប្រាថ្នា...

នាយភេត្រាងាកទៅគោងស្មាខ្មៅក និងស្ទាំងធ្វើញឹម១ រួចងាកមកសួរបិតាបុប្ផាទៀតថា :

-លោកអ៊ំ ! នៅនគរឯណោះ មានរឿងដូចម្ដេចខ្លះ ? បានជានាំគ្នាមកឱ្យលំបាកដូច្នេះ ?

លោកតាដាក់គូតអង្គុយ អវយវៈមានសភាពញ័រ១ មើលមុខអតីតសត្រូវរបស់លោកទាំងទឹកភ្នែក :

-វិណ្ណនាក្មួយប្រុស ! ឈប់ខឹងនឹងអ៊ំទៅ បំភ្លេចចោលនូវអតីតកាលដ៏ឃោឃៅរបស់យើងទៅ ពេលនេះអ៊ំជាមនុស្សគ្មានដីដើរ ដូចនាវាឥតផែចតអ៊ំបានឱ្យទុក្ខទោសដល់អ្នកយ៉ាងសែនទារុណ គួរតែអ្នកជួបអ៊ំវេលាណាវេលានោះអ្នកសម្លាប់អ៊ំចោលភ្លាម តែនេះក្មួយនៅគោរពអ៊ំ មានពាក្យសំដីល្អដល់អ៊ំ ក្មួយជាទេវតាលើជីវិតអ៊ំ ពីដើមអ៊ំជាសេដ្ឋី ឥឡូវអ៊ំជាទុគិត "កង់ត្រាចកង់ធ្នង់" វិណ្ណនា ! អ៊ំស្វែងរកដានជើងក្មួយនេះ ជាយូរថ្ងៃហើយ ។ បុប្ផាមិនព្រមយកប្ដីឯណា ក្រៅពីរូបក្មួយជាដាច់ខាត នៅឯនគរឯណោះមនុស្សលើកទ័ពមកស្ដីដណ្ដឹងបុប្ផា ផ្ទះអ៊ំទាំងមូលត្រូវភ្លៀវឡើងបាក់ខ្ទេចខ្ទីហើយដុតបំផ្លាញចោលអស់ ការណ៍នេះបណ្ដាលមកពីត្រីប្រាំពណ៌ហ្នឹងឯងបុប្ផា ស៊ីត្រីនោះ បានជាមានរូបឆោមស្រស់ល្អប្រាំពណ៌ !

វិណ្ណនាដកដង្ហើមធំ១ រួចបែរទៅសួរខ្មៅកនិងស្ទាំងថា :

-ម៉េចបងទាំងពីរឃ្លានបាយឬ ? បានជាធ្វើមុខក្រៀមផ្អះយ៉ាងនេះ ?

-ឃ្លានណាស់ ! ឃ្លានណាស់ ! អូនអើយ !

ខ្មៅកសួរទៅថៅកែសំពៅថា :

-លោកប្អូនមកដើរសំពៅនេះយូរហើយឬ ?

-បាទ មិនជាយូរប៉ុន្មានទេ ៨ខែ១០ថ្ងៃប៉ុណ្ណោះ អ្នកលបមើលគូសង្សារយ៉ាងញញឹម ។

បន្ទាប់មក វិណ្ណនាក៏បង្គាប់ទាហានឱ្យលើកម្ហូបអាហារយ៉ាងឆ្ងាញ់១មកទទួលភ្ញៀវអាស្រ័យនៅខាងក្នុងសំពៅ ។ គេបរិភោគបណ្ដើរ និយាយរឿងគេបណ្ដើរហូរហែ មានសើចមានជូតទឹកភ្នែកលាយទៅដោយពន្លឺសង្ឃឹមក្នុងអនាគតកាលរបស់គេ ។

គ្រានោះ វិណ្ណនាបានប្រាប់រឿងដែលបណ្ដាលឱ្យគេមានសំពៅថា :

-មុនដំបូងខ្ញុំស្វែងរកការងារធ្វើ ខ្ញុំសន្យាថាមិនត្រឡប់ទៅស្រុកវិញដោយគ្មានទ្រព្យសម្បត្តិទេ ខ្ញុំបានជួបពួកចោរដើរប្លន់តាមសមុទ្រស្រុកសៀមពួកនេះចិញ្ចឹមខ្ញុំ ស្រឡាញ់ខ្ញុំណាស់ ដោយគេដឹងថាខ្ញុំជាអ្នកក្លាហាន ។ មានមួយថ្ងៃ យើងលើកគ្នាទៅប្លន់ពួកឈ្មួញសំពៅដែលបើកជិតភ្នំដងរែក យើងឡើងទៅកាប់បាញ់សម្លាប់សត្រូវនោះ ។ លោកមេចោររបស់យើងបានធ្លាក់ទៅក្នុងកណ្ដាប់ដៃគេ គេយកទៅប្រហារជីវិតទៅ ទើបកូនចោរទាំងអស់គ្នាមូលមតិលើកខ្ញុំឱ្យធ្វើជានាយចៅហ្វាយលើគេរហូតមក ខ្ញុំបានដើរប្លន់តែអ្នកមានធំ១ មានសេដ្ឋីជាដើម ពួកអ្នកក្រដែលរកបាយស៊ីគ្មាន ពួកយើងចែកចាយ ឱ្យមានបាយបរិភោគ មានសំលៀកបំពាក់ យើងមិនមែនចិត្តអាក្រក់ជិះជាន់អ្នកក្រដូចគ្នាទេ !

សេដ្ឋីនៅស្ងៀម មានអាការអៀនខ្មាស និងរអែងកោតក្រែង វិណ្ណនាដ៏លើសលុប ។

ក្នុងថ្ងៃនោះ បរិយាកាសក្នុងសំពៅមានសភាពរីករាយសប្បាយ គេលេងភ្លេងច្រៀងរាំ ជាទីមនោរម្យដល់បេះដូងគូសង្សារទាំងពីរក្រៃលែង ។

# ៦
# មន្ត្រីចិនពីររូប

រូបសម្បត្តិនាងកែវបញ្ចពណ៌ មិនល្បីត្រឹមប្រទេសខ្មែរទេ គឺល្បីសុះសាយទៅដល់ប្រទេសចិនទៀត ។

ក្នុងពេលលោកសេដ្ឋីកំពុងទទួលភ្ញៀវ យ៉ាងអឹកធឹកនៅព្រះរាជធានីកម្ពុជានោះ ព្រះចៅក្រុងរាជគ្រឹះឯណោះ គឺស្ដេចស្រុកចិនបានចាត់មហាឧបរាជម្នាក់ឈ្មោះហាំង-ឆ ឱ្យលើកគ្រឿងបណ្ណាការបើកសំពៅមកសុំដណ្ដឹងនាងកែវបញ្ចពណ៌ ស្រីសក់ក្រអូបស្រុកខ្មែរធ្វើជា ព្រះអគ្គមហេសីព្រះអង្គ ។

ហាំង-ឆ លើកសំពៅពីរ បើកក្ដោងកាត់មហាសមុទ្រទាំងយប់ទាំងថ្ងៃ ។ កាលមកដល់ផែនដីនៃជាយជ្រោយសុវណ្ណភូមិហើយ ភេត្រាទាំងពីរស្រាប់តែប្រទះនឹងខ្យល់ព្យុះកំណាចមួយ បណ្ដាលឱ្យពួកនាវិកទាំងប៉ុន្មានកើតសប្បដិភ័យជ្រួលច្របល់ជាខ្លាំង ។

មហាជលយានទាំងពីរ ឃ្លេងឃ្លោងវិលវល់នៅមួយកន្លែងលើផ្ទាំងរលកធំៗដែលលូនងើបៗ ដូចផ្សោតចាប់ត្រី ជួនលោតពពាក់ពពូនបោកខ្លួនគ្រាំៗ ! គ្រាំ ! ទៅលើនាវា ។

នៅលើមហានភាល័យ ពពកខ្មៅងងឹតបាំងបិទសែងព្រះសុរិយា ។

ហាំង-ឆ និងកូនទាហានរបស់គេភ័យណាស់ ខ្លះអុជទៀនធូបបន់ស្រន់នឹកគុណកុងម៉ាស្រុកចិន ។

ភ្លៀងនិងផ្គរគ្រហឹម ហាក់នឹងមកលេបសំពៅទាំងពីរឱ្យវិនាសសូន្យទៅក្នុងសង្គ្រាមធម្មជាតិ ។

វាយុគុល្ម សាបព្រោះនូវភេរវកម្មយ៉ាងសម្បើមអស្ចារ្យ ថែមទាំងមានសត្វទឹកដ៏ធំអស្ចារ្យមួយ ហែលដេញសំពៅមហាឧបរាជនោះ ។ ពួកអ្នកដើរសមុទ្រស្រែកថា :

-ក្រពើ ! ក្រពើវើយ ! ធំណាស់ !

ហាំង-ឆ ស្មារតីរឹង បង្គាប់ទៅពួកទាំងនោះថា :

-បោះទ្រុងមាន់ ទ្រុងទាឱ្យវាស៊ីទៅ ! ឆាប់ឡើង,,,

គេក៏ធ្វើតាមបញ្ជាលោកភ្លាម តែក្រពើមិនព្រមទទួលអាហារ ចេះតែដេញកិតពីក្រោយ ។

កាលវាដេញទាន់ហើយ វាបង្អោងខ្លួនបង្កឿងសំពៅបោកផ្ទប់ទៅក្នុងផ្ទៃទឹក មនុស្សទាំងប៉ុន្មានលិចលង់ស្លាប់វិនាសអន្តរាយគ្មានសល់ សំពៅក៏ភ្លូកទើរនៅលើទីនោះ (កើតឡើងជាភ្នំ សព្វថ្ងៃគេហៅថា ភ្នំសំពៅ ឯក្រពើនោះក៏ស្លាប់ដែរ ក្លាយទៅជាភ្នំក្រពើ ទើបគេហៅថា ភ្នំក្រពើ ភ្នំទាំងពីរនេះសព្វថ្ងៃនៅក្នុងខេត្តបាត់ដំបង) ។

សំពៅមួយទៀត ខ្យល់ផាត់រសាត់ទៅជាប់ទើរលើកោះមួយ ក្នុងខេត្តបាទី មនុស្សក្នុងនាវានោះបានទម្លាក់ពួរយុថ្កាជាប់នឹងថ្ម ។ វាយុទេពិរតតែសំដែងអានុភាពខ្លាំងឡើងៗ បណ្ដាលឱ្យដាច់ពួររសាត់សំពៅ ទៅទង្គិចនឹងថ្មលិចនៅខេត្តទ្រាំង (កើតឡើងជាភ្នំ ហៅថា ភ្នំសែនលង់ យូរមកក្លាយទៅជាភ្នំសន្លុងវិញ ឯពួរដែលដាច់នោះ កកើតទៅជាថ្ម នៅក្នុងខេត្តបាទី) ។

ក្នុងពេលព្យុះសង្ឃរានោះ រស់តែ ហាំង-ឆ ម្នាក់ ដែលគាត់បានកំទេចក្តារមួយបន្ទះតោងបណ្តែតខ្លួនតាមរលកសមុទ្រ មហាឧបរាជអណ្តែតទៅជួបទូកពួកអ្នកនេសាទ ។

-វុឺយ មនុស្សលង់ទឹកជួយគ្នាផង ! ម្នាក់ពោលឡើង ។

ខណៈនោះខ្លួនមន្ត្រីចិន ក៏បានឡើងទៅដេកលើទូក ។ គាត់នៅដង្ហើមផ្តេត១ ពុំដឹងខ្លួនប្រាណអ្វីឡើយ ។

បុរសពីរនាក់ ម្នាក់អុំមុខ ម្នាក់អុំកន្សៃ អុំមួយសន្ទុះក៏មកដល់សំពៅដែលចតយ៉ាងសង្ហារនៅក្បែរឆ្នេរ ។ គេឃើញលោកថៅកែ វ័ណ្ណនា ឈរអើតមើលពីលើមក ។ វ័ណ្ណនាដឹងជាអ្នករងគ្រោះ ក៏បង្គាប់ឱ្យលើកខ្លួនយកទៅថែទាំលើនាវ៉ា ។

មិនយូរប៉ុន្មាន ឧបរាជចិន ក៏ដឹងខ្លួនមានដង្ហើមចេញចូល មានភ្នែកបើកមើលគេ មានសម្លេងខ្សាវ១ ប្រុងនិយាយសាកសួរ តែមន្ត្រីចិនរូបនេះនិយាយទៅគ្មាននរណាស្តាប់ដឹងថា ដូចម្តេចសោះ ព្រោះជាភាសាចិន ។ ក្នុងបណ្តាពួកនាវិកនោះ មានគ្នាយើងម្នាក់ចេះនិយាយ ចិន ។ លុះមស្តាប់គ្នាបានហើយក៏ធ្វើជាអ្នកបកប្រែ ។

បុរសរងគ្រោះនិយាយថា ខ្លួនជាមហាឧបរាជឈ្មោះ ហាំង-ឆ ស្តេចក្រុងរាជគ្រឹះចាត់ឱ្យដណ្តឹងនាងកែវបញ្ចពណ៌,,, និងបរិយាយពីខ្យល់ព្យុះលង់លិចស្លាប់មិត្តសេនាអស់ ។

វ័ណ្ណនានិងកែវបុប្ផាដឹងដូច្នោះ ក៏អស់សំណើច ។

ថៅកែសំពៅយើង បង្ហាញរូបភរិយាខ្លួនទៅមន្ត្រីចិនថា :

-នេះកែវបញ្ចពណ៌ នាងជាប្រពន្ធរបស់ខ្ញុំទៅហើយ ! បើស្តេចក្រុងចិនចង់ដណ្តើមនាង ខ្ញុំថ្វាយបាន ម៉េចចង់ដណ្តឹងទេ ?

អ្នកបកប្រែបាននិយាយប្រាប់ហាំង-ឆ សព្វសេចក្តី ហាំង-ឆ ឆ្លើយវិញជាភាសាចិន ទើបបកប្រែពោលថា :

-មហាឧបរាជនិយាយថា "ខ្ញុំស្មាននាងនៅក្រមុំ បើនាងមានប្តីទៅហើយគឺជាការចប់ត្រឹមនេះ ដូច្នេះសូមលោកឱ្យខ្ញុំនៅសំណាក់ផង ទម្រាំមានសំពៅគេទៅស្រុកចិន ខ្ញុំនឹងត្រឡប់យកសេចក្តីទៅក្រាបទូលព្រះចៅវិញ,," ។

ហាំង-ឆ ជាវិរជនមួយរូបរបស់មហាក្សត្រស្រុកចិន គាត់បានលួចសរសើររូបឆោមលោមពណ៌កែវបុប្ផាតែក្នុងពោះ ហើយមានមនោសញ្ចេតនាស្រឡាញ់នាងទៀតផង ។

តាំងពីថ្ងៃនោះមក វ័ណ្ណនាបើកដៃឱ្យមហាឧបរាជរស់នៅជាមួយ បុរសនេះបានបញ្ចេញឫកពារស្រគត់ស្រគំ ជាមនុស្សត្រឹមត្រូវគួរឱ្យទុកចិត្តមែន ។

ថ្ងៃមួយហាំង-ឆ បានឃើញនាវ៉ាមួយគ្រឿងលើកទង់ជ័យចិនបើកដល់ជិតសំពៅមេចោរភ្នំដងរែក ។

មន្ត្រីចិន ក្រឡេកឃើញសម្លាញ់គេម្នាក់នៅក្នុងសំពៅមកដល់ថ្មី ទើបគេស្រដីទៅអ្នកបកប្រែថា :

-ប្រហែលជាសំពៅស្តេចក្រុងចិន ឱ្យមកតាមខ្ញុំហើយ !

ហាំង-ឆ ស្រែកទៅកាន់នាវ៉ាទើបមកដល់នោះ ជាភាសារបស់គេ ហើយដែលភាសាយើងមានសេចក្តីថា :

-អេ ! អេ ! ងី-ខាយ ចូលមក ! យើងជួបគ្នាហើយ !

បន្តិចមកសំពៅងី-ខាយ ក៏បានមកឯបនឹងសំពៅសំឡាញ់របស់គេ ថ្លែងរឿងហេតុអំពីគ្រោះថ្នាក់ទាំងប៉ុន្មាន រួចនាំងី-ខាយ ឱ្យស្គាល់ វិណ្ណានានិងនាងសក់ក្រអូប តាមការគួរសម ។

ងី-ខាយ ស្រាយពាក្យទៅប្រាប់មហាឧបរាជ មានសេចក្តីថា :

-ព្រះចៅក្រុងរាជគ្រឹះ ទ្រង់ព្រួយព្រះទ័យណាស់ ទន្ទឹងមើលផ្លូវលោកយូរពេកបានជាទ្រង់ត្រាស់បង្គាប់ឱ្យយើងមកតាម ហើយទ្រង់មានព្រះរាជឱង្ការថា ទោះយ៉ាងណាក៏ដោយ ត្រូវតែយើងយកនាងទៅថ្វាយឱ្យបាន ឥឡូវបើនាងមានប្តីដូច្នេះ យើងគិតយ៉ាងណា ?

កិច្ចអ្នកទាំងពីរជំនុំគ្នានេះ ពុំមាននរណាដឹងឡើយ ។

ហាំង-ឆ ខ្សឹបប្រាប់ងី-ខាយថា :

-ពួកយើងត្រូវប្រុងការឱ្យស្រេច ស្តេចស្រុកខ្មែរក៏សព្វព្រះរាជហឫទ័យលើរូបនាងដែរ ។ សព្វថ្ងៃនេះ កងទ័ពស្តេចកំពុងដេញតាម រកដាននាងដូច្នេះក្នុងរាត្រីនេះយើងគិតលួចពង្រាត់នាងទៅប្រទេសយើងឱ្យបាន !

ហាំង-ឆ គិតជាស្រេច ក៏ឆ្លងមកសំពៅខ្មែរវិញ មកប្រាប់ វិណ្ណានាតាមពាក្យអ្នកបកប្រែថា :

-ស្អែកខ្ញុំលាមិត្តហើយ ដូច្នេះល្ងាចនេះ គួរយើងជប់លៀងភោជនាហារឱ្យសប្បាយ ព្រោះយើងមិនងាយបានជួបគ្នាវិញទេ !

វិណ្ណានាក៏ព្រមតាម ដ្បិតមិនដឹងឧបាយកលរបស់អាចឹក ។ អ្នកចូលទៅជួបភរិយាខាងក្នុងថា :

-បុប្ផ ! ហាំង-ឆ លាយើងទៅស្អែកហើយ គេឱ្យយើងរៀបស៊ីផឹកដើម្បីនឹងលាគ្នា បងចាត់ឱ្យអូនជាអ្នកបំរើភ្ញៀវ !

ភរិយាស្វាមីក៏ចាត់ចែងរកម្ហូបចំណី រៀបតុកៅអីជាពីរជួរយ៉ាងវែង ហើយក៏អញ្ជើញមន្ត្រីទាំងពីររូបនិងទាហានរបស់គេទាំងប៉ុន្មានឱ្យមកអង្គុយត្រៀបត្រាជាមួយខ្មែរយើង ។ ពួកចិនយកសុរាមកឱ្យខ្មែរ ចាក់ជូនខ្មែរទៀត ។ ខ្មែរធ្លាប់តែស្រាខ្លួនមិនសូវឆ្ងាញ់ លុះប៉ះស្រាស្រុកចិនក៏ផ្អែមមាត់ ដាក់មួយតយហើយថែមមួយតយទៀត ។

ក្នុងខណៈនោះ យើងមិនអាចសំគាល់ទឹកមុខវិណ្ណានាជាយ៉ាងណាទេ វិណ្ណានាដឹងខ្លួន ឬក៏ផឹកស៊ីដោយឥតបើគិត ?

យើងឃើញនាយសំពៅ សេដ្ឋី ខ្វែក ស្ទាំងនិងក្រុមខ្មែរយើង ស្រវឹងវីវក់ឆ្កាដៃឆ្កាជើង និយាយព្រោកប្រាជ្ញសើចសប្បាយ លាន់ទ្រហឹងអឺងអាប់ ។ នរណាលេងភ្លេងក៏លេងទៅ នរណារាំរែកក៏រាំរែកទៅ ។

ហាំង-ឆ ខ្សឹបនឹង ងី-ខាយ ថា :

-បានការហើយយើង ពួកវាស្រវឹងឥតសល់ម្នាក់ទេ ចំណែកនាងជាប្រពន្ធវានោះ ឯងទុកឱ្យអញចុះ ឯងមានដាក់ថ្នាំពុលនៅក្នុងស្រាខ្លះទេ ?

-មានដាក់ដែរ,,, ងីខាយឆ្លើយ ។ បន្តិចទៀតពួកវានឹងរលំដួលអស់ហើយ !

ដូចពាក្យចិនថាមែន មិនយូរប៉ុន្មាន នៅលើតុ កនខ្មែរទាំងអស់ ក្រាបក្បាលរណែល ចិនឥតស្រវឹងដល់ម្នាក់សោះ ។ នៅសល់តែកែវបញ្ចពណ៌ម្នាក់ឯង មិនចេះផឹកស្រា នាងឈរកណ្តាលជួរតុកៅអី ភ្នែកនាងចោលអាការរន្ធត់អស្ចារ្យ កាលបើឃើញ ហាំង-ឆ បោះជំហានមួយៗមកជិតនាង ។

វេលានោះព្រះច័ន្ទថ្ងៃ ១៣ កើត បានចោលដួងរស្មីភ្លឺត្រចះត្រចង់មកលើផ្ទៃឆ្នេរជលសាទាំងមូល ។ កំទេចប្រាក់ល្អិតញ័រៗស្ថិតលើទឹក មេឃ

ស្រឡះស្អាតលេចភ័ក្ត្រខែយ៉ាងក្រឡង់ សំឡឹងសំឡក់មកចំដបស្រា ដែលនៅឈរត្រៀបត្រាលើតុ ។

កែវបុប្ផាភ័យខ្លាំងក្រៃ ស្រែកហៅប្ដីថា :

-បងវ័ណ្ណនា ! ឱ ! ប្ដីសម្លាញ់ភ្ញាក់ឡើង គេចាប់ប្អូនឥឡូវហើយ !

វ័ណ្ណនាឥតកម្រើកខ្លួនតិចតួចឡើយ ។

ធីតាងាកទៅរកខ្មែរកនិងស្ងាំង ឪពុកនាង អ្នកទាំងបីដួលគរលើគ្នាដបស្រានៅដៃ ។

សម្លេងមាណវីព្រួគ្រលួច ក្នុងរាត្រីស្ងាត់ជ្រងំ ។ ជុំវិញកល្យាណី ពុំមានខ្មែរណាម្នាក់ដឹងខ្លួនសោះ ។

នៅឆ្ងាយពីសំពៅ រលកបោកផ្ទប់ទៅនឹងផ្ទាំងសិលា ឮសូរគួរឱ្យស្រងេះស្រងោចពន់ពេក ។ បុប្ផារត់គេចជាន់ទៅលើពួកស្រវឹង ពួកនេះនៅមិនដឹងខ្លួនទៀត ។

ហាំង-ឆ ដេញចាប់នាងទាល់តែបាន នាងបម្រះមិនរួចសោះ ។ បុប្ផាខំយកបាទាទៅទាត់តុ ទន្រ្ទាំកែវយ៉ាងណា ក៏ឥតខ្មែរណាម្នាក់ជួយនាងបានឡើយ ។

រលត់សង្ឃឹម នាងសក់ក្រអូបស្រដីថា :

-នែ ! អាមន្ត្រីសាមាន្យ ! ឯងមិនត្រូវមកលួចប្រពន្ធគេទាំងអំណាចដូច្នេះទេ អញមិនព្រមទៅជាដាច់ខាត បើឯងយកអញទៅបាននោះ គឺយកតែសំបកខ្លួនប៉ុណ្ណោះ ឯជីវិតអញនៅជាប់នឹងប្ដីអញជាដរាប !

ពាក្យនេះចិនស្ដាប់មិនបានសោះ តែចិនអាចសំគាល់កាយវិការ និងទឹកមុខរបស់នាងបាន វាគ្រាន់តែដឹងថានាងមិនព្រមតាមបំណងរបស់វាជាដាច់ខាត ។

មហាឧបរាជនិយាយប្រាប់នារីថា :

-នាងជាស្រីល្អផុតផែនដី ! ក្នុងនាមរបស់ខ្ញុំ ខ្ញុំសូមនាងជាគូប្រចាំជីវិត ខ្ញុំមិនអាចដកខ្លួនថយពីកែវបានទេ គឺបេះដូងរបស់បងទេតើ ដែលនាំជើងបងមកដណ្ដើងអូនក្នុងខណៈនេះ អូនស្រឡាញ់បងមក បងមិនឱ្យអូនលំបាកអ្វីទេ,,,

បុប្ផាស្ដាប់ពាក្យចិនមិនដឹងថាដូចម្ដេច មានតែឃី-ខាយទេ ដែលពួនជិតនោះ បានស្ដាប់ភាសាបាន ។

ឃី-ខាយ ឮមហាឧបរាជចង់នាងយកផ្ទាល់ខ្លួនឯង ក៏នឹកឆេះមួយរំពេចថា "អានេះក្បត់នឹងព្រះរាជឱង្ការ" ។

ប៉ុន្តែមន្ត្រីនេះ នៅស្ងៀមចាំសង្កេតកិរិយាមិត្តខ្លួនតទៅទៀត ។ បុត្រីសេដ្ឋីខំបម្រះពេកទៅជាអស់កម្លាំងទន់ដៃទន់ជើង សមនាងភ័យស្រាប់ផងស្មារតីនិងសតិទាំងប៉ុន្មាន ក៏ស្រុះស្រួលបបួលគ្នារត់ចោលម្ចាស់ស្រីអស់ ។

ហាំង-ឆ គិតថា "បានដៃអញយប់នេះហើយ"

ឃី-ខាយ ឆេះក្នុងចិត្តទ្រាំមិនបាន ក៏ស្រែកថា :

-ឯងរឹតនាងខ្លាំងពេក បានជានាងសន្លប់ដូច្នេះ ឯងថយចេញ ទុកឱ្យអញលើកនាងទៅទុកក្នុងបន្ទប់ រួចយើងនឹងស្រាយយុថ្កាលើកក្ដោងចេញដំណើរឥឡូវនេះ !

ថាហើយក៏ទៅចាប់ទាញនាងលើក ហាំង-ឆចាប់ដៃជាប់ :

-ឯងគ្មានអំណាចអ្វីមកប៉ះពាល់ខ្លួនស្រីនេះទេ !

-យី ! សម្លាញ់ឯងប្រចណ្ឌនាងមកលើអញឬ? នាងមិនមែនជារបស់នរណាទាំងអស់ នាងជាកម្មវត្ថុនៃបេសកកម្មរបស់យើង បើឯងស្រឡាញ់នាងនេះផ្ទាល់ខ្លួន អញនឹងសម្លាប់ឯង ក្នុងព្រះបរមនាមនៃព្រះចៅរាជគ្រឹះ !

លោកហិតគ្របមុខជិត ហាំង-ឆ ហូតដាវខ្វាក ធី-ខាយ យកអាវុធការពារភ្លាម ។ អ្នកទាំងពីរឈរយកស្ថានភាពរៀងខ្លួន រួចក៏គេកាប់គ្នាផុងឥតបង្អង់ អាមួយលោតដេញ អាមួយបញ្ចេញក្បាច់យ៉ាងអស់ពីចិត្ត ធី-ខាយរងខាងលើមិនជាប់ ក៏បណ្ដាលឱ្យមុតសាច់ស្មា រហែកអាវចេញឈាមមក ។ ហាំង-ឆ មានប្រៀបជាងជាដរាប ធី-ខាយស្ទុះឡើងទៅលើគែមសំពៅដើម្បីនឹងដោះខ្លួន តែដាវមហាឧបរាជរហ័សណាស់ បានចាក់ចំដើមទ្រូង ធី-ខាយៗផ្ងារទៅក្រោយ ធ្លាក់ទៅក្នុងទឹក លុះដល់នូវមរណកាលនាគ្រានោះ ។ ពួកទាហានចិន ទាំងប៉ុន្មាននៅស្ងៀមឥតកម្រើកខ្លួនឡើយ ។

ហាំង-ឆ សម្លាប់មិត្តរបស់ខ្លួនបានហើយ ក៏លោតមកលើចំណីជាទីស្នេហារបស់គេ ។ ឱកាសនោះ នាងកែវបញ្ចពណ៌ បានដឹងស្មារតីឡើងវិញ ។

នាងមិនបានដឹងមហាឧបរាជសម្លាប់ធី-ខាយទេ តែនាងបានឃើញដាវហាំង-ឆ មានឈាមជាប់នៅនោះ ។ នារីមានការភិតភ័យជាថ្មី... ហាំង-ឆ ចាប់ដៃនាងអូសឆ្លងទៅសំពៅមួយទៀត ដៃម្ខាងក្របួចសក់មាណវីជាប់ដៃម្ខាងទៀតចង្អុលទៅពពួករេហ៍ពលរបស់ ធី-ខាយ ហើយស្រែកប្រកាសថា :

-អ្នករាល់គ្នានៅឱ្យស្ងៀម ខ្ញុំជាអ្នកកាន់អំណាចអាជ្ញាសឹកមកដណ្ដើមស្រីនេះយកទៅថ្វាយម្ចាស់ផែនដីយើង ធី-ខាយ ក្បត់ គិតស្រឡាញ់នាង បានជាខ្ញុំសម្លាប់វាចោល !

ព្ទូរកុក ! កាំបិតស្នៀតមួយស្រាប់តែដោតឆ្កឹងនៅលើក្ដារជិតជើងមហាឧបរាជៗក្រឡេកមើលទៅលើដំបូលសំពៅខ្មែរ ក៏ឃើញវីណ្ណនាមហាសេដ្ឋី ខ្វែក ស្ទាំង និងទាហានគេប្រមាណ ៨ នាក់ កាន់ដាវ ខ្លះកាន់ធ្នូ តម្រង់មក ។

វីណ្ណនាស្រែកពីចម្ងាយថា :

-ហាំង-ឆ លែងប្រពន្ធអញឱ្យឆាប់! ពួកអញនេះអម្បាញ់មិញស្រវឹងទឹកមាត់ទេ ឯស្រាពួកអាចង្រៃឯងនោះ ពួកអញឥតស្រវឹងឡើយ ។

អ្នកបកប្រែរបស់វីណ្ណនា ក៏រហ័សពន្យល់តាមពាក្យនេះទៅ មាហាឧបរាជចិនៗបើកភ្នែកធំៗ ងាកឆ្វេងងាកស្ដាំ ។

គួរឱ្យសរសើរវីណ្ណនាមែន ។ ក្នុពេលស៊ីផឹកអ្នកមានលាក់សេចក្ដីសង្ស័យមួយយ៉ាងជ្រៅ ព្រោះឃើញមន្ត្រីចិនទាំងពីររូបឱ្យសញ្ញាភ្នែករកគ្នាម្ដងៗ ។ អ្នកមិនផឹកស្រាសោះ ផឹកដោយលបចាក់ចោល អ្នកកេះប្រាប់គ្នាជិតៗនោះឱ្យដឹងខ្លួនជាមុនស្រេច រួចវីណ្ណនា និងអ្នកដឹងខ្លួនទាំងប៉ុន្មានក៏ធ្វើជាស្រវឹងដួលរណែល សូម្បីនាងបុប្ផភ័យស្រែកហៅយ៉ាងណា ក៏វីណ្ណនាធ្វើត ធ្វើថ្លង់ រហូតដល់មន្ត្រីទាំងពីរកាប់ដាវគ្នាទៀត ក៏អ្នកនិងមិត្តរបស់អ្នកធ្វើមិនដឹងខ្យល់ទៀត ប៉ុន្តែគង់មានខ្មែរខ្លះជ្រុលខ្លួនផឹកទាល់តែស្រវឹងមែនៗ ព្រោះគេប្រាប់មិនទាន់ ។

ឯបុប្ផានាងឥតដឹងប្ដីសន្ធប់ពុតដូច្នេះទេ ។ ឯវីណ្ណនាសោត ក៏រកឱកាសប្រាប់ប្រពន្ធមិនទាន់ដែរ ។ នារីក្រឡេកឃើញប្ដីនិងបក្សពួកនាងភ្ញាក់ឡើង ឃុំពួកចិនវិញបាន ក៏រួសរាយសប្បាយអនេកបរិយាយ ។

វីណ្ណនាស្រែកថា :

-កនយើងចូរសម្លាប់អាខ្មាំង កុំទុកពូជវា !

លោកមេទ័ពចោរ បោះពួយទៅមុន ខ្លះទាញខ្សែយោលខ្លួនទៅប្រយុទ្ធជាបន្តៗគ្នា ។ មួយរំពេច សូរអាវុធក៏ព្ទូរប្រាវ ! ប្រាវ ! កាប់ចាក់គ្នាពេញបន្ទុក ដាវវីណ្ណនានិងដាវហាំង-ឆ ស្អិតដូចតាំងម៉ែ វីណ្ណនា ប្រទះធុងស្រា វត្ថុអ្វីៗនៅជិត អ្នកឆ្លៀតលើកគ្រវែងបោកទៅត្រូវអាចឹកស្លាប់ ឬទ្រម

ខ្លួនដួលប្រកាច់នៅនឹងកន្លែង ។ នាងកែវបញ្ចពណ៌ធ្លាក់ទៅក្នុកណ្ដាប់ដៃអាចឹកម្នាក់ដុះក្បាលពោះស្ពឹង ធ្លាក់ដោះម្ខាង១ប៉ុនចង្អេរ ក្បាលវាទំពែករលោងមានពុកមាត់ពីរវែងធ្លាក់សំយេះមកក្រោម ។

អាហ៊ានេះឱបស្រីខ្មែរដើរថយក្រោយ ដៃវាការពារដរាប ។

ខ្វែកនិងស្ទាំង ដេញអាចឹកឆាយស្អិត ដើម្បីដណ្ដើមនាងឆវី នារីឯកយើង ។ តែអាចឹកឆាយគប់តែដៃម្ខាង រួបក្បាលទាសាទាំងពីរទង្គិចផ្ទប់ទៅក្បាលពោះដួលស្ដូកទៅក្រោមជើងរបស់វា។ អ្នកឯទៀតដេញព្រួទៅទៀតចឹកឆាយចាក់ព្រួកស្លាប់សូន្យ ។ ចិនគ្នាច្រើនណាស់ មានអាតួហ៊ាមួយទៀតគ្មានដាវទេ លោតមកគុនដំបងខ្វាល់ចុះខ្វាល់ឡើង គ្មាននរណាកាប់ត្រូវឡើយ ព្រោះយើងចូលមិនដល់ខ្លួនវា ។ ទាហានដៃស្ដាំឈ្មោះខ្មៅរបស់វណ្ណា ជាស្ដេចចោរកាលពីដើម ឥឡូវជាកូនចោររបស់វណ្ណា បានកាន់ច្បូកផ្លែដែកមុខបី ចូលទៅប្រយុទ្ធជាមួយចឹកអៀ ដែលជាអ្នកពូកែគុណដំបង ។ អ្នកទាំងពីរប្រឡូកគ្នាអស្ចារ្យ ខ្មៅតោងចឹកអៀជាប់ ព្រោះចឹកអៀភ្លាត់ស្នៀត ។ ទីបំផុត ខ្មៅចូលជិតអាចឹកនេះមិនបានទេ ។ ខ្មៅបានខ្សែចង្វាយក៏បោះទៅ ទាក់កចឹកអៀជាប់ រួចអូសទម្លាក់ទៅក្នុងទឹកព្ទស្ទូរប្រឡង ។ នៅលើខ្សែ ស្រាវក្ដោងឯណោះ វណ្ណាដាវមួយនៅដៃកំពុងដេញកាប់ ហាំង-ឆ ដែលតោងខ្សែទៅលើអាកាស ។ អ្នកទាំងពីរប្រទាញប្រទង់គ្នាខាងលើមើលទៅគួរឱ្យស្ញើបខ្លួនពេកណាស់ ។ ជួនគេឃើញវណ្ណារបូតដៃវារមក តែអ្នកមានស្មារតីតោងខ្សែខាងក្រោមជាប់វិញ ។ វណ្ណា មិនត្រូវការតយុទ្ធនឹង ហាំង-ឆ ទៀតឡើយ អ្នកលោតព្រឹសមកដលដី រួចរត់ទៅរកចឹកឆាយដែលកំពុងជាប់ដៃនឹងមិត្តយើងជាច្រើននាក់ ។

យើងព្រួតគ្នាសម្បើមណាស់ ទម្រាំទម្លាក់អារុំធចឹកឆាយបាន។ នៅដៃទទេ ឆាយមិនសូវមានកម្លាំងទេ ខ្វែក និងស្ទាំងងើបពីសន្លប់វិញក៏បោកសំរុកដាល់ពោះអាប៉ិកំប៉ោងព្ទឹប១ ទាល់តែវាដួលក្រឡើត តើតមុជក្បាលជាប់ទៅនឹងចង្កូតសំពៅ ។

យើងដណ្ដើមយកបុប្ផាបានវិញ ។ វណ្ណាកៀកភរិយាជាប់នៅដៃ អ្នកស្រែកបង្គាប់ថា :

-ថយទៅសំពៅយើងវិញជាប្រញាប់ !

ពេលដោះខ្លួនរត់នេះ ចុងដាវគូបដិបក្សមួយ បានហើរទៅដោតចំកណ្ដាលខ្នងលោកសេដ្ឋី វណ្ណា និងខ្វែករហ័សជួយគ្រាហ៏លោកបានមកដល់សំពៅ ឯស្ទាំងដេញតាមសម្លាប់អ្នកលបធ្វើឃាតនេះបាន រួចលោតក្រោយទៅក្នុងនាវា ។ មិត្តយើងហត់ដង្ហើមផ្ដេត១រៀងខ្លួន ។ វណ្ណា បញ្ជាឱ្យលើកក្ដោងស្រាវយុថ្កា ជួនមានខ្យល់បក់មួយរឹបធំមក សំពៅ វណ្ណា ក៏បោះពួយកាត់ផ្ទាំងរលកធំ១ ឆ្ពោះមុខទៅទិសបូពា៌,,,

ក្នុងនាវា នាងសក់ក្រអូបនិងវណ្ណា ព្រមទាំងខ្វែកនិងស្ទាំង បានឈរជុំវិញខ្លួនលោកសេដ្ឋី ដែលដេកស្ដូកមានកាំបិតមួយជាប់នៅកណ្ដាលខ្នង ។

-កែវបុប្ផ,,, សម្លេងសេដ្ឋី ។ កូនស្រីសម្លាញ់ឪពុក ឪពុកអស់បានឃើញមុខនាងទៀតហើយ នាងផ្ញើខ្លួនលើវណ្ណាឱ្យល្អ នាងកុំបែកពីគេឡើយ គេមានចិត្តវិសេសល្អណាស់ វណ្ណា,,, កូនប្រុស !,,, ឪពុកចាកឋានឥឡូវនេះហើយ អ្នកមើលថែទាំបុប្ផាឱ្យល្អផង កម្មពៀរឪពុក សូមឱ្យវិនាសទៅតាមព្រលឹងឪពុកវេលានេះចុះ,,, កូន !,,, កូនទាំងពីរ !,,, សូរយំយ៉ាងរំពងបានខ្ចាយចេញពីមាត់បុប្ផា និងវណ្ណា រួចជលនេត្ររបស់ខ្វែកនិងស្ទាំងបានស្រោច

ស្រប់ស្នងពាក្យយំរំពងនេះ ។ ខាងក្រៅសូររលកធំៗបានឱ្យភេរវសព្ទគួរឱ្យរន្ធត់ជាក្រៃលែង ។

លើមហាមេឃពពកទាំងផ្ទាំងៗ បានគ្របមុខលោកខែបាត់ អន្ធការក៏ត្រដាងសំណាញ់ខ្មៅ ដេរដាសពាសពេញមហាប្រថពី ។

អស្ចារ្យមែន ! ពេលសំពៅកំពុងបើកគេចខ្លួនរត់ពីពួកចិននោះ ពួកចោរខ្លះដែលស្រវឹងខ្លាំងមិនទាន់ភ្ញាក់នៅឡើយ នៅដេកជ្រងំ និយាយម្នាក់ឯង ឬទារស្រាផឹកទៀត ។

## ៧
## វិលត់ខន្ធគឺវិលត់ទុក្ខ

ព្រឹកស្អែកឡើង សំពៅហាំង-ឆ បានដេញទាន់សំពៅវិណ្ណនា នៅតាមជួរភ្នំដងរែក ។

ហាំង-ឆ បង្គាប់ឱ្យបាញ់កាំភ្លើងធំ នាវាខេមរៈបែកបាក់ជាច្រើនអន្លើ ។ នាយភេត្រាបញ្ជាឱ្យយកចង្កូតចូលខាង ដើម្បីបបួលគ្នារត់ឡើងគោក ។

កែវបុប្ផាកាន់ដៃស្វាមីនិយាយថា :

-ប្តីអើយ ! គ្នាយើងតិចណាស់ តែនៅតែដៃមុខជាស្លាប់ទាំងអស់គ្នាមិនខាន ណាមួយសពលោកប៉ា ក៏យើងមិនបានចាត់ចែងយ៉ាងណានៅឡើយ

នាវាមកដល់ជិតមាត់កំពង់ អ្នកខ្លះបោះយុថ្កា អ្នកខ្លះស្រាវក្តោង អ្នកខ្លះទៀតទម្លាក់ទូកតូចៗទៅក្នុងទឹក ទាំងអស់គ្នាធ្វើការឥតទំនេរដៃ ពួកសត្រូវបាញ់មួយក្តុងមក ត្រូវចំខ្លួនសំពៅបណ្តាលឱ្យស្លាប់មនុស្សច្រើននាក់ ។ វិណ្ណនាទាញដៃប្រពន្ធ រុញនាងឱ្យចុះទៅក្នុងលង់បុត្រមួយដោយនិយាយថា :

-សពលោកប៉ាធ្លាក់បាត់ទៅក្នុងទឹកហើយ យើងត្រូវប្រញាប់ដោះខ្លួនរត់ អូនទៅមុនចុះ ចាំបងទៅក្រោយ !

បុប្ផាផ្ទប់មុខយំនឹករលឹកបិតានាង ។ ខ្ញែកនិងស្ទាំងអុំទូកតូច នាំម្ចាស់ស្រីទៅដល់ត្រើយគោក រួចនាំនាងឡើងលើច្រាំង ។ ឯវិណ្ណនា គ្មានទូក អ្នកបង្គាប់ឱ្យបាញ់មួយគ្រាប់សងទៅវិញ ទើបអ្នកបបួលគ្នាដែលសល់ពីស្លាប់ទាំងប៉ុន្មាន លោតទៅក្នុងទឹកហើយហែលតម្រង់នាង ។ វិណ្ណនាបានជួបបុប្ផា អ្នកទាំងពីកាន់ដៃគ្នាមើលទៅសំពៅរបស់ខ្លួន ដែលកំពុងលិចសន្សឹមៗទៅក្នុងមហាជលធី ។

គ្រានោះយើងឃើញហាំង-ឆ និងចឹកឆាយចតសំពៅ។ វាទាំងពីរអុំទូកតូចតាមយើងទៀត ឯពួកកម្មករចិនច្រើនរយនាក់ ក៏ចេញទូកមកតាមក្រោយជាលំដាប់ ។

ពូខ្ញែក ស្រែកជេរចិនថា :

-អាចិនចង្រៃ !,,, ចៅហ្វាយអើយ ! វាមកតាមព្យាបាទយើងដល់លើគោកទៀតហើយ !

-ទៅ ! ទៅ ! ពួកវាច្រើនណាស់ វិណ្ណនាបង្គាប់ ។

សមាជិកវិណ្ណនា នៅសល់គ្នាហាសិបនាក់ប៉ុណ្ណោះ ។ គ្រប់គ្នារត់ដួលៗដោយអស់កម្លាំងពេក ។ ស្រីកំសត់និងប្តីនាងបែកញើស ដំណើរទ្រេតទ្រោតដូចមនុស្សស្រវឹងស្រា ។ យើងទាំងអស់គ្នារត់ចូលទៅក្នុងព្រៃភ្នំ សំលៀកបំពាក់រហែករយីរយ៉ៃមិនគួរមើលឡើយ ។

យើងមកឈប់សម្រាកក្រោមផ្ទាំងសិលាដ៏ធំមួយ ។ ខ្មៅកនៅតែខឹង ហើយរង្វ៉ូវម្នាក់ឯងថា :

-ហ៊ឹ អាចិនចង្រៃនេះដេញឯងមិនលែង ទើសម៉ែអីវា ?

ស្ទាំងតបថា :

-អាខ្មៅកដេកឱ្យស្ងៀមទៅ អាប្រកាច់ទាញ អញកំពុងផ្ទៀងត្រចៀក ស្ដាប់ ក្រែងពួកវាដឹងកន្លែងយើងនេះ ទំ ! ឮសូរអ្វីទេ ?

វិណ្ណនាផ្ទប់ត្រចៀកទៅនឹងដើមឈើ រួចបញ្ជាក់សេចក្ដីយ៉ាងញាប់ញ័រថា :

-យើងនៅទីនេះមិនបានទេ សេះប្រមាណមួយពាន់មកពីទិសបូពិ ! ...

បុប្ផាភ្ញាក់នឹងពាក្យ សួរទៅគូជីវិតនាងថា :

-ទ័ពសេះឬ ? ពួកចិនគ្មានសេះទេ មានតែទ័ពហ្លួង ! បើទ័ពហ្លួង ពេលនេះយើងវរធំហើយ,,, ឱ ! ទេវតាអើយ ! ឱ្យខ្ញុំរត់ទៅខាងណា ? ងាក ទៅខាងលិចពួកចិន ងាកទៅខាងកើតទ័ពខ្មែរជាសត្រូវ,,, បើខ្ញុំមានស្លាបទៅ រ៉ា ខ្ញុំនឹងយោងប្ដីខ្ញុំឱ្យផុតពីមនុស្សលោក,,, ស្រីកំព្រាឱបប្ដីជាប់ នាងយំ ប្រុស នាងយកដៃអង្អែលសក់នាង អ្នកថើបសក់ស្រីដោយសម្លេងញ័រៗថា :

-បុប្ផា ! សក់អូននៅក្រអូបដូចដើម បងមិនចោលអូនទេ បងតស៊ូ លុះត្រាជីវិតបងក្ស័យណាអូនស្នេហ៍ !

សហជីវិនម្នាក់ដែលនៅឈរយាមលើដើមឈើ បានសម្រូតចុះមក រួចរត់ទៅប្រាប់ចៅហ្វាយខ្លួនថា :

-ខាងកើតទ័ពហ្លួងមានគ្នាច្រើនណាស់ ខាងលិចទ័ពអាហាំង-ឆ ដូច្នេះយើងរត់ទៅទិសខាងណា ? បើចុះទឹកក្រពើឡើងលើខ្លាយ៉ាងនេះ ?

វិណ្ណនាឈ្ងោកមុខទៅដី មុខនេះហាក់នឹងស្រក់លោហិតមក អ្នកងើប មុខឡើងថា :

-ខាងជើងភ្នំ ខាងត្បូងសមុទ្រ យើងយកភ្នំចុះ បើម៉េចៗជើងយើង ដល់ដី ច្រមុះយើងនៅលើគោកមានខ្យល់ដក,,, ទៅ,,, មិត្ត ! ស្លាប់រស់ជា មួយគ្នា !

យើងទាំងអស់គ្នា កន្ត្រាក់អាវុធរៀងខ្លួន ហើយរត់ទៅទិសខាងជើង

-បុប្ផា ! ឱ្យបងពរអូនឬ ?

-ទេ ! បង,,, បងក៏ហត់ ប្អូនក៏ហត់ មិនអីទេប្អូនរត់បាន !

កល្យាណីរត់បានតែបន្តិច ក៏ដួលស្រូស ប្ដីនាងលើកនាងដាក់លើស្មា រួចពោលថា :

-ឱប្អូនមាសបង !,,, បងសួរអូនអម្បាញ់មិញ អូនថារត់បាន !

អ្នកលើកភរិយាបញ្ជិះលើស្មា រួចប្រាប់នាងថា :

-អូនតោងសក់ក្បាលបងឱ្យជាប់ !

នៅតាមក្រោយ ពួកទាហានចិនដើររុករុលត្បុលវាយព្រៃផ្សៃ រកពួក វិណ្ណនា ។

-វ៉ឺយ ! វាទៅទិសខាងជើងហើយ ដេញតាមទៀត ! ចិនម្នាក់ស្រែក

វិណ្ណនាធ្ងន់នឹងប្រពន្ធ ណាធ្ងន់នឹងសំពាយស្បៀងអាហារ ម្ដងៗអ្នក ព័ន្ធជើងរកកលនឹងដួល ។

ឃើញប្ដីទ្រុឌទ្រោម ក្រោមការកំហែងរបស់ទុព្វលភាពដូច្នោះ កល្យាណីស្រីទុគិតអង្វរប្ដីថា :

-អ្នកប្ដីសម្លាញ់អូន ! ដាក់ខ្ញុំចុះ ខ្ញុំនឹងបានសម្រាលកម្លាំងអ្នកខ្លះ,,,

វីណ្ណនាព្រមដាក់ឱ្យភរិយាដើរ អ្នកហូតឆ្មិកាមួយពីចង្កេះហុចទៅជាយា :

-អូន ! កាំបិតនេះអូនទុកការពារខ្លួន នៅខណៈដែលបងមិនអាចជួយអូនបាន !

នារីទទួលអាវុធស្បៀតនៅចង្កេះសំពត់របស់នាង ។ ទាំងអស់គ្នាក៏យាត្រាទៅមុខដរាប ។

មិនយូរប៉ុន្មាន ហាំង-ឆ និងក្រុមរបស់វាបានតាមទាន់ វីណ្ណនា ទាញដៃបុប្ផយកទៅលាក់ក្នុងគុម្ពោតមួយ ប្រាប់នាងថា :

-បុប្ផ ! អូននៅត្រង់នេះពួននៅឱ្យស្ងៀម បងចេញទៅតយុទ្ធនឹងអាហាំង-ឆ,,,

ថាហើយ យុវជនក៏ហូតដាវស្ទុះទៅប្រឡូកជាមួយគូបដិបក្ស ដែលកំពុងព័ទ្ធចាប់មិត្តរបស់អ្នក ។ សូរដាវនិងសម្រែកមនុស្សធ្វើឱ្យផ្អើលពួកសត្វក្រាបក្នុងស្មៅ និងម្រឹគទាំងឡាយក្នុងទុរគមនោះ ។

ខ្មែរស្លាប់មួយម្តង១ ថ្វីដ្បិតតែបានប្រហារពួកខ្មាំងជាច្រើននាក់ដែរ ។ ខ្មែកជាប់ដៃនឹងអាមួយនោះ ស្មាំងអស់ដៃ ចិនកាប់ត្រូវមួយដាវ ឱពុទ្ធោ ! ស្មាំងជំនិតលោកសេដ្ឋីពីដើមជាអតីតបច្ចាមិត្តរបស់ វីណ្ណនា ឥឡូវឈានជើងចូលទីអវសាន ទៅកាន់វិញ្ញាណក្ខន្ធលោក សេដ្ឋីទៅហើយ ។ ខ្មែកឃើញស្មាំងស្លាប់ ឈឺចិត្តខ្លាំងក្រៃស្ទុះទៅកាប់អានោះត្រូវមួយដាវសងវិញស្លាប់ដូចគ្នា ។ ខ្មែកក្រឡេកឃើញអាចឹក ឆាយលោតមក ខ្មែកមិនហ៊ានតដៃគេចខ្លួនចេញ ខ្មែកបានឱកាសលោតតោងកចឹកឆាយជាប់ រួចយកដៃទាំងពីររឹតកឆាយ ។ បម្រះ បោកខ្មែកលាន់ភឹង ខ្មែករត់ទៅ ឆាយដេញកិតពីក្រោយ ។ គ្រោះ អាក្រក់របស់ចឹកឆាយមកដល់ តានេះជាប់ជើងទៅក្នុងជង្ហុកមួយ ដូចដីរីសាជាប់ផុង រើខ្លួនមិនរួច ។ ខ្មែកញញឹមបួងដៃពីនាយមក មកដល់តាំងលោតទាំងជើងពីរធាក់ត្រូវឆាយ បង្កប់ទៅក្នុងអណ្តូងភក់បន្ថែមទៀត ។ ខ្មែកកន្ត្រាក់បានឈើងាប់មួយកំណាត់ ក៏តាំងសំពងវាយឮសូរដូចផ្គរ ឆាយស្រែកដូចខ្លាត្រូវរបួស ដៃខ្មែកពិតអាចឹកឆាយទាល់តែស្លាប់ផ្ងារពោះចង្រ្កាងនៅទីនោះ ។ ខ្មែករត់ដោះខ្លួន ដ្បិតមានគ្នាគេមកទាន់ ។

នៅលើទីប្រយុទ្ធឯណោះ វីណ្ណនា និងហាំង-ឆ កំពុងជាប់គ្នាយ៉ាងសាហាវ ។ អ្នកទាំងពីររមៀលខ្លួនធ្លាក់ទៅក្នុងជង្ហុកមួយយ៉ាងធំ ។ ដោយហត់ខ្លាំងពេក វីណ្ណនាក៏ប្រហែសឱ្យសត្រូវចាក់ត្រូវមួយដាវចំស្មាខាងឆ្វេង ។ ថ្វីដ្បិតតែមានរបួស វីណ្ណនានៅមានប្រៀបជាង ហាំង-ឆខាងកលល្បិច ។ អ្នកវាយខ្ទាំងរបូតអាវុធពីដៃ ។ អ្នកហៀបនឹងតម្រង់ចុងដាវចំបេះដូងមហាឧបរាជទៅហើយ ស្រាប់តែមានសម្លេងមួយស្រែកយ៉ៃ ពីគុម្ពោតព្រៃមកថា :

-ជួយ ជួយ ! បងវីណ្ណនាជួយប្អូនផង !,,, អ្នកកម្លោះរហ័សដូចរន្ទះលោតឡើងមកទីខាងលើ រួចរត់តម្រង់ទៅពួកចិនបីនាក់ដែលកំពុងចាប់ប្រអូសប្រទាញយកថ្លើមប្រមាត់របស់អ្នកទៅ ។

វីណ្ណនារត់ទៅទៀតមិនរួច ព្រោះពិសកំពុងជិះជាន់ពលភាពអ្នកយ៉ាងឃោឃៅ ។ ឈាមហូរកាន់តែច្រើនឡើង១ អ្នកផុតសេចក្តីសង្ឃឹម បុរសចោលភ្នែកមើលជុំវិញខ្លួនឃើញ មិត្តទាំងប៉ុន្មានស្លាប់អស់គ្មានសល់ ។ ពួកចិនដោះខ្លួនថយទៅវិញអស់ ខ្មែកស្វែងរកវីណ្ណនា ភ្នែកគាត់ក្រឡេកមើលចៅហ្វាយ ហៀបនឹងលោតទៅជិត ស្រាប់តែមានអាចឹកម្នាក់ ដែលត្រូវរបួសមិនទាន់ស្លាប់ហូតកាំបិតស្នៀត ចោល វឹមកត្រូវកំភួនជើងខ្មែកដួលព្រូស ។ សំណាងខ្មែកល្អដែរ ចេះមិនត្រូវចំកណ្តាលខ្នង បុរសយើងឈឺចាប់ក្រៃលែង

ខំចាប់ទាញអាវុធដកពី សាច់ញ៉រសក់ក្បាល ។ បានកាំបិតភ្លាម គាត់ក៏ចោលសំដៅវាវិញ...

ក្នុងពេលខ្មៅកកំពុងដកកាំបិតនេះ វីណ្ណនាបានដើរទាំងទទ្រេតទទ្រោតទៅឆ្ងាយបន្តិចហើយ វីណ្ណនា ដើរតាមស្រមោលភរិយារបស់អ្នក ។

ឯហាំង-ឆ ដឹងកូនទាហានចាប់កែវបញ្ចពណ៌បានហើយ ក៏មិនរវល់ដេញតាមវីណ្ណនា វាគិតថាវីណ្ណនាត្រូវរបួសគង់តែស្លាប់មិនខាន ហាំង-ឆ រត់ទៅកាន់សំពៅខ្លួនវិញ ក៏បានជួបនាងបុប្ផានៅទីនោះ ។

បុរសកំសត់ ខំស្រែកហៅគូជីវិតថា :

-បុប្ផា ! បុប្ផា ! អូន !... អូននៅឯណា ?

គួរឱ្យខ្លោចចិត្តអាណិតយុវជនរងគ្រោះនេះណាស់ ជើងអ្នកដើរទៅដោយលំបាក ដោយធ្ងន់រកអ្វីផ្ទឹមពុំបាន ។ ពូខ្មៅក ឮសូរមាត់ ចៅហ្វាយខ្លួនស្រែកហៅប្រពន្ធជិតនោះដែរ ក៏ខំស្រែកហៅវីណ្ណនាបន្តទៀត តែវីណ្ណនា តតឆ្លើយតបសោះ ចេះតែបោះជំហានទៅមុខជាដរាប ។ នេះមកពីបុរសពុំបានឮសម្លេងពូខ្មៅក ។

ចៅកែសំពៅខំដើរទាល់តែបានមកកាន់ឆ្នេរជលសាគរ ។

យុវជនមើលឃើញភរិយានៅលើសំពៅ ឃើញសត្រូវកំពុងចាប់នាងចង ។ នាងបម្រះរួចដោយនាងមានលាក់កាំបិតស្នៀតមួយ អាស្រ័យកាំបិតនោះហើយ បានជានាងមានឱកាសរត់ចុះរត់ឡើងនៅលើដំបូលនាវា ។

វីណ្ណនាត្រេកអរ ក៏តាំងស្រែកហៅប្រពន្ធថា :

-បុប្ផា ! បុប្ផា... ! អូន ! អូនមកវិញ...

-បងវីណ្ណនា ! បងវីណ្ណនា !... នាងឆ្លើយ ។

បុប្ផា ត្រូវចិនដេញពាក់ពពូន បណ្ដាលឱ្យនាងខានឃើញមុខប្ដី ។

គួរឱ្យអស្ចារ្យមែន! រំពេចនោះ ស្រាប់តែកងទាហានសេះរបស់ព្រះថោង បានមកឈប់ត្រៀបត្រានៅមាត់សមុទ្រ ។

នាយកងទ័ពម្នាក់ ឃើញបុរសកំសត់យើងមានរបួស ស្រែកហៅប្រពន្ធក្ដែងៗដូច្នោះ ក៏សួរថា :

-នែអានេះ ! ឯងហៅបុប្ផា ! បុប្ផាកូនសេដ្ឋីឬ ?

យុវជនក៏ឆ្លើយតាមត្រង់ក្រែងគេអាណិត គេជួយសង្គ្រោះខ្លួនបាន ។

អ្នកឆ្លើយដោយគោរពថា :

-លោកដ៏មានបុណ្យ ! បុប្ផាហ្នឹងហើយ ! គឺនាងកែវបញ្ចពណ៌ បុត្រីសេដ្ឋី នាងជាប្រពន្ធខ្ញុំសព្វថ្ងៃ ឥឡូវពួកចិនចាប់នាងដាក់សំពៅទៅថ្វាយស្ដេចស្រុកចិនហើយ... លោកជួយខ្ញុំផង... នុំហ្ន៎ ! នាង !

ឮដូច្នោះ នាយកងទ័ពខ្មែរ ក៏បង្គាប់ឱ្យពួកទាហានបាញ់ពួកចិន ដែលកំពុងដេញចាប់កែវបញ្ចពណ៌លើសំពៅមិនទាន់បាន ។ ព្រួញហើរទៅផ្ដាច់ជីវិតទាហានចិនប៉ុន្មាននាក់ ស្លាប់មួយរំពេច ។ ឯបុប្ផាក៏រួចខ្លួន ឈរវេរាៗម្នាក់ឯង ត្រេកអរក្នុងបីតិជាអនេក នឹកស្មានមានគេសប្បុរសមកជួយនាង ។

ហាំង-ឆ ភ័យណាស់ ឃើញទ័ពខ្មែរមកកកកុញលើច្រាំង ។ វាបង្គាប់ទាហានឱ្យលើកក្ដោង ស្រាវពួរដកយុថ្កាជាប្រញាប់ វារត់ទៅលើដំបូលប្រវាចាប់បុប្ផាកំពូលនារីស្រុកខ្មែរជាប់ តែព្រួញយ៉ាងត្រង់បំផុតរបស់មេសឹកខ្មែរបានមកប្រឡេះយកខ្លួនហាំង-ឆ ព្រួញឈឺបចំទ្រូងធ្លាយដល់បេះដូងវា ។ ហាំង-ឆ ផ្ងារទៅក្រោយធ្លាក់ទឹកគ្រាំដល់នូវមរណកាល ។

បុប្ផាបានឱកាស ក៏លោតទៅក្នុងទឹក ឯពួកចិនក្នុងសំពៅមិនហ៊ានតនាវាចេះតែលឿនទៅមុខដោយកម្លាំងក្ដោង ដែលគេទាញខ្សែលើកឡើងទៅឆ្ងាយៗផុតពីដែនដីកម្ពុជា ។

យុវភរិយាហែលទឹកបណ្តើរ ស្រែកហៅប្តីបណ្តើរថា :

-បងវីណ្ណនា ! បង,,, ឱបងយើងជួបគ្នាវិញហើយ !

ពុទ្ធោ ! បុប្ផាមិនដឹងប្តីនាងត្រូវរបួសទេ,,, អ្នកប្រុសថ្លៃរបស់នាងកំពុងហុចដៃទៅតោងបាទជើងមច្ចុរាជហើយ ។ វីណ្ណនាញញឹមចាំទទួលភរិយា អ្នកបោះហត្ថាទាំងគូទៅរកស្រី ។

បុត្រីសពលោកសេដ្ឋីឡើងមកលើគោក ។ នាងរត់យ៉ាងលឿនស្ទុះទៅរកប្តី ដែលរត់ដួល១មកទទួលនាង ។

គូជីវិតទាំងពីរឱបរឹតគ្នាយ៉ាងតឹងដៃ ។ បុប្ផាភ្ញាក់នឹកឃើញប្រុសថ្លើមថ្លៃនាងមានសភាពខ្សោយទៅ១ ដោយមានលោហិតស្រក់តក់១ធ្លាក់ទៅដី ។

បងវីណ្ណនា ! បងត្រូវរបួស ?

-អូន ! បងត្រូវរបួសក្នុងពេលប្រយុទ្ធ !

បុប្ផាព្រួដូច្នោះ ហាក់ដូចភ្លឹកបាត់វិញ្ញាណសូន្យ ។ នាងរៀបនឹងគ្រាហ៏ខ្លួនប្តីឱ្យអង្គុយ ស្រាប់តែមានដៃកំណាចអប្រិយ៏មួយមកកញ្ឆក់នាងដាក់ទៅលើខ្នងសេះ នាងស្គាល់ជាទាហានសេះមួយរូប ។

ស្រីល្អខំបម្រះយ៉ាងណាក៏ពុំរួច ។ ទាហាននោះគឺលោកមេសឹកលោកបញ្ចេញមុខកាចគួរឱ្យខ្លាច លោកសើចរួចនិយាយថា :

-កែវបញ្ចពណ៌ ស្រីសក់ក្រអូប យើងតាមរកនាងយូរថ្ងៃហើយឥឡូវយើងយកនាងទៅថ្វាយព្រះកុមេរុរាជ ! ថាប៉ុណ្ណោះ មេសឹកហួតដាវបំបោលសេះទៅចំវីណ្ណនា ដែលកំពុងវារជើងបួនអង្វរសុំប្រពន្ធពីគេ។ មេសឹកកាប់បុរសជាប្តីបុប្ផាមួយដាវភឹប អាសូរ វីណ្ណនាណាស់ អ្នកទទួលផ្លែអាវុធយ៉ាងសែនទារុណ របស់ខ្មាំង ដោយពុំបានលាភរិយាឡើយ ។ អ្នករំលាយក្ខន្ធរំលាយទុក្ខ រំលាយសេចក្តីស្នេហាពីកល្យាណីនាគ្រានោះ ។

កែវបុប្ផាស្លុតស្មារតី នាងស្រែកថា :

-លោកអើយ ! ស្លាប់ប្តីខ្ញុំហើយ ! បងវីណ្ណនា បង!,,,

ទឹកមុខនាងឡើងក្រហមដោយទោសៈ ។ សេចក្តីសងសឹកបានមកស្ថាបនាក្នុងវីរភាពរបស់នាងមួយរំពេច ។ នាងធ្វើជាទន់ខ្លួន ។ មេទ័ពខំឱបនាងជាប់មិនឱ្យធ្លាក់ពីខ្នងសេះ ។ វាស្មានថានាងសន្លប់ ទើបចេះតែបរជំនិះទៅ ដោយឥតគិតក្រែងរអែង ។

បុប្ផា លុះបានឱកាស នាងលូកដៃបន្តិចម្តង១ទៅដកកាំបិតស្នៀតដែល វីណ្ណនាឱ្យនាង ហើយនាងកំសត់នឹកពាក្យប្តីនាងមិនភ្លេច "អូន ! កាំបិតនេះអូនទុកការពារខ្លួននៅខណៈដែលបងមិនអាចជួយអូនបាន" ។

ព្រួសូរឈឹប បុប្ផាចាក់ទាហានកំណាចយ៉ាងពេញទំហឹងដៃ ចំកណ្តាលទ្រូងវា ។ អានោះធ្លាក់ពីខ្នងសេះ នាងធ្វើជាម្ចាស់សេះម្តង នាងមេម៉ាយបំបោលអស្សពាហ៏ទៅជួបសព្វវីណ្ណនា ។ នាងលោតចុះពីជំនិះទៅឱបប្រុស :

-វីណ្ណនា បង !,,, បងស្លាប់ចោលអូនហើយ !

ខ្លួនបុគ្គលដេកស្តូកស្តឹងលើពសុធា ។ អ្នកចែកឋានហើយ អ្នកមិនបានព្រួសម្លេងហៅរបស់ភរិយាទេ ។

កែវបញ្ចពណ៌ បង្ហូរទឹកនេត្រជាឈាម បង្ហូរសូរសៀងជាលោហិតនាងនិយាយថា :

-បង ! ប្អូនបានបំពេញសេចក្តីសងសឹកជូនបងហើយ ! អ្នកថ្លៃអញ្ជើញទៅឱ្យសុខចុះ ហើយសូមរង់ចាំមើលផ្លូវប្អូនផង !

ខណៈនោះពួកពលទ័ពហ្លួងមកដល់ ។ បុប្ផាឥតដឹងខ្លួន,,, នាងហូតកាំបិតកាត់សក់មួយដុំ យកទៅដាក់ក្នុងកណ្តាប់ដៃប្តី :

-អ្នកប្ដីកំសត់ ! នេះជាដួងព្រលឹងរបស់ប្អូន ដែលភ្ជាប់និស្ស័យជាមួយបង សក់នេះជាសុភមង្គលរបស់យើងនៅក្នុងភពថ្មី វដ្ដសង្សារនេះមិនបានឱ្យសេចក្ដីសុខដល់យើងទេ !

ទិព្វតន់ ហៀបនឹងលើកអាវុធធ្វើឃាតខ្លួនឯង ស្រាប់តែមានសម្លេងមួយគំហកថា :

-នែនាង ! ប្ដីនាងស្លាប់ហើយ ! នាងត្រូវរកប្ដីទៀត យើងយកនាងទៅថ្វាយស្ដេច !

បុប្ផាភ្ញាក់នឹងវាចានេះ នាងឆ្លើយតបទៅថា :

-ខ្ញុំជាមនុស្សមានទោស ខ្ញុំត្រូវតែស្លាប់ លោកបរសេះមកមានឃើញខ្មោចចៅហ្វាយរបស់លោកទេ ?

-យើងឃើញហើយ... នាងកុំភ័យអ្វី កុំថានាងសម្លាប់មនុស្សម្នាក់ សូម្បីនាងសម្លាប់មួយពាន់នាក់ ក៏នាងគ្មានទោសដែរ !

យុវតីកាត់សក់ក្រអូបរបស់នាងមួយដុំ បោះទៅឱ្យពួកកងទ័ព ដោយសម្លេងថា :

-សូមលោកយកសក់នេះទៅថ្វាយព្រះថៅងចុះ ឯរូបខ្ញុំ ជីវិតខ្ញុំលោកយកទៅមិនបានជាដាច់ខាត ខ្ញុំសូមលាលោកហើយ...

ថាប៉ុណ្ណោះ ស្រីសក់ក្រអូបចាប់ដងឆុរិកាយ៉ាងមាំ ចាក់កខ្លួនឯងយ៉ាងក្លាហាន អនិច្ចា ! កែវបញ្ចពណ៌ទន់ខ្លួនដួលត្មោល លោហិតហូរខ្ចាយទៅលើព្រះធរណី ។

ពួកទាហានឃាត់មិនទាន់ ផុតសង្ឃឹម ម្នាក់ៗអួអាក់ក្នុងចិន្ដាក្រៃលែង ។ ពួកគេបបួលគ្នាជីករណ្ដៅមួយធំ រួចលើកសពប្ដីប្រពន្ធទាំងពីរដាក់ទៅក្នុងរណ្ដៅតែមួយ ។

លប់ដីកប់ខ្មោចរួចស្រេច ពួកគេក៏នាំសក់នាងបុប្ផាមួយដុំនោះ ត្រឡប់ទៅកាន់ព្រះរាជធានីវិញ ។

នៅក្នុងព្រៃឯណោះ យើងឃើញបុរសម្នាក់ពួនលបមើលនូវកិច្ចការនិងព្រឹត្តិការណ៍ដែលទើបកន្លងទៅថ្មីៗនេះ ។

នរណាបុរសនោះ ?

គឺពូខ្វែកមិត្តយើង ! ពូខ្វែកត្រូវរបួសចេះតែខំតាមដានវីណ្ណា រហូតមក ។ គាត់មកទាន់ឃើញនាងបុប្ផាសម្លាប់ខ្លួនឯង ។ គាត់រន្ធត់ញាប់ញ័រក្នុងអង្គអាត្មា ស្ទើរបាត់វិញ្ញាណនៅទីនោះ ។ ខ្វែកឃើញទាហានទៅផុតអស់ហើយ គាត់ក៏ដើរទ្រើបៗមកកាន់ទីផ្នូរ ។ គាត់ឱនកាយគោរព រួចបង្ហូរជលនេត្រហូរហៀរថា :

-ក្មួយទៅឱ្យបានជួបគ្នា ក្នុងភពដ៏ជាទីក្សេមក្សាន្តចុះ ! រឿងរបស់អ្នកទាំងពីរមានតែខ្ញុំទេ ដែលជាសាក្សី ។

ពូខ្វែកដើរប្រមូលដុំថ្មតូចៗ យកមកគរពូនជាផ្នូរឱ្យបានខ្ពស់ រួចគាត់អង្គុយសូត្រធម៌ ទាំងដំណក់ឈាមដែលរអិលចេញពីស្នាមរបួស ទាំងគ្រាប់ពេជ្រមូលថ្លាដែលហូរខ្ចាយពីរង្វង់ភ្នែករបស់គាត់ ។ ខ្វែក សូមខមាទោសពីជីវិតអ្នកទាំងពីរ ។

បន្ទាប់មកទាសាសពលោកសេដ្ឋីត្រាច់រង្គាត់ក្នុងព្រៃ ប្រទះអ្នកដំណើរគាត់សុំដោយសាររទេះគេត្រឡប់ទៅស្រុកវិញ ។ ខ្វែកស្វែងរកវីណ្ណនី ជាប្អូនវីណ្ណា ជួបហើយគាត់បានបង្ហោនមនោសញ្ចេតនា ប្រាប់វីណ្ណនី ពីមរណភាពរបស់បងនាងសព្វគ្រប់ហើយ បាននិយាយរឿងបុប្ផាទាំងស្រុងឱ្យនាងស្ដាប់ទៀត វីណ្ណនីយំសោកជាខ្លាំង អាឡោះអាល័យជីវិតទាំងពីរពុំស្បើយ ថ្ងៃនោះនាងកុមារីពុំបរិភោគអាហារចំណីអ្វីឡើយ ។ ពូខ្វែកជួយពន្យល់ និង លួង

លោមនាងកុំឱ្យយំសោកពេក គាត់ព្រមទទួលរ៉ាប់រងចិញ្ចឹមក្មេងកំព្រានេះទុកដូចកូនបង្កើត...

កន្លងដប់ឆ្នាំក្រោយមក ខ្វែកខ្លាយទៅជាតាចាស់ម្នាក់ដុះពុកមាត់ស្រមូម ដើរបានតែកាន់ឈើច្រត់ ។

ថ្ងៃនេះតាខ្វែកនាំនាងកញ្ញាវ័ណ្ណនីបរទេះ ទៅមើលផ្នូរវ័ណ្ណនា និងបុប្ផានៅឆ្នេរជលសាគរ ដែលគាត់បានចំណាំដឹងក្នុងជំនាន់ដើម ។

ឥទ្ធិវធម្មជាតិ បានធ្វើទីត្រង់នោះឱ្យស្រុតដីស្ទើរតែសំគាល់ជាផ្នូរមិនបាន ។ គាត់ចាត់ចែងពូនដី ពូនថ្មធ្វើផ្នូរមិនខ្លាចនឿយហត់ មិនគិតជរាភាពរបស់គាត់ឡើយ ។

អនុស្សាវរីយ៍ផ្នូរកំសត់នេះហើយ ដែលតាខ្វែក និងនាងវ័ណ្ណនី ឈរធ្វើគារវភាពហើយរំលឹករឿងផ្សងព្រេងក្នុងអតីតកាល ។

ខ្វែកនិងនាងមាណវី សម្តែងវន្ទនាការចំពោះវិញ្ញាណក្ខន្ធនៃជីវិតរួមផ្នូររួចហើយ ក៏ឡើងទៅលើរទេះ ។

កញ្ញាវ័ណ្ណនីជាអ្នកបរ តាចាស់អង្គុយខាងក្នុង ។

ព្រះសុរិយាទេរទន់ទ្បេបហៀបអស្តង្គតទៅហើយ ឯយានចរ តាខ្វែកក៏ខំបង្វិលកង់ទាំងពីរយ៉ាងលឿន ដើម្បីប្រញាប់ទៅកាន់លំនៅឋានអាត្មាវិញ

ម្តងៗ វ័ណ្ណនីដេញគោថា :

-ហ្ស៊ុយ ! ហ្ស៊ុយ !...

ទីបំផុតព្រលប់ក៏មកដល់...

**ចប់**